# ចន្ទកុមារជាតក



នេះកាលកណ្ឌហាលព្រាហ្មណ៍នាំចន្ទកុមារ និងសុរិយកុមារទៅបូជាយញ្ញ
តែត្រូវព្រះឥន្ទ្រគំរាមសំពងក្បាលនឹងដំបង ក៏បានដោះលែងកុមារទាំងពីរវិញ


ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ

**កុល ផេង**



**ព.ស. ២៥៦៣**

# ចន្ទកុមារជាតកពិស្តារ

## អធិបតីក្នុងការរៀបរៀង

## បណ្ឌិត គុល ផេង

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## អ្នកបកប្រែពីអដ្ឋកថាភាសាបាលី

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## ក្រុមជំនុំពិនិត្យ

*បណ្ឌិត* **គុល ផេង** *ប្រធាន*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា**

*ព្រះញាណកោសល* **យ៉ន សេងយៀត**

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ គុយ**

*លោក* **លឹម លឿម**

*លោក* **ដុង សុភឿន**

*លោក* **ឧិក្ខ សៅ**

*លោក* **សំណាង សំណាក់**

*លោក* **ស៊ន់ គឹមឈន់**

*លោក* **ប៉ាល់ ចំរើន**

*លោក* **ហ៊ុន ពិសេស**

*លោក* **ហាន សុខេមនុ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ិន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **ម៉ម ម៉ានិត** *អនុប្រធាន*

*លោក* **ឃុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

## រចនាសម្ព័ន្ធពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
## ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សាមឿន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សារ៉េន** *សមាជិក*

*សាស្ត្រាចារ្យ* **ជិត ជន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា គ្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុង សុវណ្ណា** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ ភុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោក* **ហ៊ាត ណាហាំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមន្ត** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **ភុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **ចាន់ ហួរ** *សមាជិក*

*លោក* **ហួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ គុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **សំណាង សំណាក់** *សមាជិក*

*លោក* **ដុង សុភឿន** *សមាជិក*

*លោក* **ហ៊ុន ពិសេស** *សមាជិក*

*លោក* **ស៊ន់ គឹមឈន់** *សមាជិក*

# សូមថ្វាយព្រះរាជកុសល
# ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង
# ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## *បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***ចន្ទកុមារជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *សូម* **ព្រះករុណាជាអម្ចាស់** *អនុមោទនានូវមហា*

*កុសល ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះ បារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុងអនាគត និងដោយអំណាចគុណាបុណ្យ ព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈ ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុ សក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលថែរក្សា* **ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ជាទី គោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ មានព្រះរាជសុខភាពល្អ បរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណ វាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាន នូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**ក្មុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមថ្វាយព្រះរាជកុសល
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## *បពិត្រសម្តេចព្រះមហាក្សត្រីជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***ចន្ទកុមារជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសលដោយ ព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះ បារមីនៃព្រះសម្មាសម្ពុទ្ធ*

*គ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុង អនាគត និងដោយអំណាចគុណបុណ្យ ព្រះរតនត្រ័យ ទេវតាថែរក្សា ព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហា ក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយ ក្នុងលោក សូមជួយអភិបាលថែរក្សា* **សម្តេចព្រះមហាក្សត្រ នរោត្តម សីហមុនី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ ទ្រង់មានព្រះរាជ-សុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្ម យឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បី ទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍ តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **សម្តេចព្រះមហាក្សត្រ** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជ-ហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**ភុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមគោរពជូនមហាកុសល
# សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## *សម្ដេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាខ្ញុំបាទ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តីជយមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ* **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *និង* **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូនមហាកុសល ដែលខ្ញុំបាទបានដឹកនាំការរៀបរៀងចងក្រងនូវសៀវភៅ "***ចន្ទកុមារជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនានេះ ។ សូម* **សម្ដេច** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ។ ដោយតេជះគុណានុភាពនៃព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុសក្តិសិទ្ធិ ក្នុង លោកសូមជួយបីបាច់ថែរក្សានិងប្រសិទ្ធិពរជ័យជូន* **សម្ដេច** *និង* **លោកជំទាវ** *ព្រមទាំង* **បុត្រាបុត្រី** *និង* **ចៅ** *ៗ ជាទីស្រឡាញ់របស់* **សម្ដេច**

*សូមមានសុខភាព ល្អបរិបូណ៌ ជន្មាយុយឺនយូរ បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកត្រើយសុខសន្តិភាព និងការអភិវឌ្ឍឲ្យសម្បូរសប្បាយ រុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្តនូវវិរិយភាពដ៏អង់អាចរបស់* **សម្តេច** *ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែងរកសេចក្តីសុខជូនចំពោះប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុងព្រះរាជាណាចក្រកម្ពុជាយើង នាំមកនូវភាពចម្រើនរុងរឿង នាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគតកាល ។*

*សូម* **សម្តេចអគ្គមហាសេនាបតីតេជោ** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** *ប្រកបដោយសិរីមង្គល វិបុលសុខមហាប្រសើរ ព្រមទាំងទទួលបាននូវធម៌ដ៏ប្រសើរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*រាជធានីភ្នំពេញ,*
*ថ្ងៃ ៩ កើត ខែ អស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**ភុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# បុព្វកថា

*រឿងចន្ទកុមារនេះ គឺជាជាតកមួយក្នុងមហាទសជាតក៍ ដែលមានប្រភពដើមជាភាសាបាលីនៃគម្ពីរអដ្ឋកថា ។ យើងដឹងហើយថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានអ្នកចេះភាសាបាលីជាស្ពានសម្រាប់ឆ្លងទៅស្វែងយល់នូវពុទ្ធោវាទជាភាសាបាលីនេះ មានចំនួនតិចតួច ។ បើទុករឿងក្នុងជាតកទាំងអស់ឲ្យនៅជាភាសាបាលី ដូច្នេះជាឧបសគ្គដ៏ធំសម្រាប់អ្នកសិក្សាភាគច្រើន រួមទាំងសិស្ស និស្សិត និងបញ្ញវន្តទាំងអស់ដែលមិនបានសិក្សាភាសាបាលី ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាយើង ក៏ធ្លាប់មានសៀវភៅសង្ខេបទសជាតក ដែលប្រែនិងរៀបរៀងដោយលោក* **ឈឹម ស៊ុម** *កាលពីឆ្នាំ ១៩៥៩ មួយក្បាលគ្រប់ទាំង ១០ រឿងរួចមកហើយឃើញថា មានសេចក្ដីសមល្មមគ្រប់គ្រាន់សម្រាប់ពុទ្ធសាសនិកជនសម័យនោះសិក្សារៀនសូត្រ តែមកដល់សម័យបច្ចុប្បន្ននេះ រឿងសង្ខេបទសជាតកនោះ មិនទាន់ជួនល្មមដល់តម្រូវការនៃការស្រាវជ្រាវរបស់សិស្ស និស្សិត បញ្ញវន្ត និងពុទ្ធសាសនិកនៅឡើយ ។*

*សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មើលឃើញពីតម្រូវការនេះ ថាជាការចាំបាច់បំផុតក្នុងការចូលរួមចំណែកជួយអប់រំសង្គម ទើបខ្នះខ្នែង ចាត់ចែង រៀបចំបកប្រែនិងរៀបរៀងចន្ទកុមារជាតកនេះ*

ម្តងទៀតឲ្យមានសេចក្តីពិស្តារ តាមច្បាប់ដើមក្នុងអដ្ឋកថា ជាភាសាបាលី ក្នុងគោលបំណងជួយបំពេញបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់ សិក្ខាកាមគ្រប់កម្រិតនិងដល់ពុទ្ធបរិស័ទគ្រប់រូប ។

ការរៀបរៀងសៀវភៅនេះ ដំបូងយើងប្រែពីភាសាបាលីមកជាភាសាខ្មែរ បន្ទាប់មក យើងចាប់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ដោយប្រើសំនួនវោហារតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួនណាត ជោតញ្ញាណោ ជាគោល ។ ខ្លឹមសារសេចក្តី យើងប្រើពាក្យពាយសាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ដល់អ្នកសិក្សាគ្រប់កម្រិត ។ ម្យ៉ាងទៀត ពាក្យពិបាកខ្លះដែលជាប់ដោយភាសាបាលី ដែលខ្មែរយកមកប្រើជារាជសព្ទ និងសង្ឃសព្ទ យើងមិនអាចចៀសវាងបាន ក៏ត្រូវរក្សាទុក ដោយដាក់លេខយោងពន្យល់នៅផ្នែកខាងក្រោមនៃទំព័រ ។

ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងខ្លឹមសារសេចក្តីក្នុងសៀវភៅនេះ ទោះបីយើងខំប្រឹងប្រែងពិនិត្យកែជាច្រើនលើកច្រើនសា ដោយផ្ចិតផ្ចង់ក៏ដោយ ក៏គង់មានចំណុចខ្វះចន្លោះផ្នែកអក្ខរាវិរុទ្ធ និងសេចក្តីនៅមានផ្តាំផ្តង់ខ្លះ ៗ មិនខាន ។ សូមអស់លោកអ្នកអានឃើញខុសត្រង់ណា មេត្តាជួយកែតម្រូវក្នុងលក្ខណៈស្ថាបនាឲ្យបានរីកចម្រើន ដើម្បីបានជាក្បួនខ្នាតទុកសម្រាប់កុលបុត្រសិក្សាតទៅអនាគត ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមចែករំលែកនូវកង់ការមហាកុសលដែលកើតឡើងពីការបកប្រែរៀបរៀងសៀវភៅចន្ទកុមារ

ជាតកពិស្ដារនេះ ថ្វាយ ប្រគេន ជូនដល់អស់លោកអ្នកដែលបានកាន់សៀវភៅនេះអាន និងដល់បុព្វការីជន ញាតិមិត្រ សាច់សា លោហិតទាំងអស់ក្នុងសង្សារវដ្ដ សូមឲ្យលោកអ្នកមានគុណទាំងនោះ បានសម្រេចនូវសម្បត្តិ ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេព្តា និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។
សូមសត្វលោកទាំងពួងបានប្រកបដោយសេចក្ដីសុខជានិរន្តរ៍តទៅ ។

រាជធានីភ្នំពេញ,
ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨

**ក្នុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី១

### កំណើតព្រះចន្ទកុមារ


ឧបាយទេវទត្តធ្វើឃាតព្រះសាស្តា..........................................១

ព្រះសាស្តាប្រោសជីវិតពួកខ្មាន់ធ្នូ..........................................៣

មូលហេតុនៃនិទាន....................................................................៦

ចន្ទកុមារកាត់ក្តីយុត្តិធម៌..........................................................៧

ព្រះរាជាសុបិនឃើញកពតាវត្តិង្ស............................................៩

ខណ្ឌហាលព្រាហ្មណ៍ប្រាប់វិធីបូជាយញ្ញ..............................១១


## ជំពូកទី២

### សំណោកមហាជន


ព្រះរាជាបង្គាប់ឲ្យចាប់ពួករាជបុត្រ.......................................១៦

ព្រះរាជាបង្គាប់ឲ្យចាប់ពួករាជធីតានិងមហេសី......................១៨

ព្រះរាជាបង្គាប់ឲ្យចាប់សេដ្ឋី ៤ នាក់........................................១៩

ព្រះរាជមាតាបិតាអង្វរព្រះរាជា..........................................២៣

ចន្ទកុមារអង្វរព្រះបិតា.......................................................២៨

ខណ្ឌហាលព្រាហ្មណ៍តឿនស្តេចឲ្យឆាប់បូជាយញ្ញ..............៣១

វសុលកុមារបុត្រនៃចន្ទកុមារពិលាប....................................៤៣

ពួកស្រីស្នំពិលាប...................................................................៤៦

មហាជនពិលាប.....................................................................៥០

ព្រះមាតាគោតមីទេវីពិលាប................................................៥៤

ចន្ទកុមារពិលាប....................................................................៥៥

ចន្ទាទេវីអង្វរព្រះបាទឯករាជ..................................................៦០

## ជំពូកទី៣

### រាជបុរសអភិសេកចន្ទកុមារឡើងគ្រងរាជ្យ

ចន្ទាទេវីតាំងសច្ចាធិដ្ឋាន.......................................................៦៧

សក្កទេវរាជសម្មុតស្តេចឲ្យដោះលែងសព្វសត្វ......................៦៩
មហាជនគប់សម្លាប់ខណ្ឌហាលព្រាហ្មណ៍............................៧០
មហាជនទម្លាក់ស្តេចទៅជាជនចណ្ឌាល..............................៧១
ពិធីរាជាភិសេកចន្ទកុមារ....................................................៧២
ស្តេចចន្ទកុមារជូនស្បៀងដល់ឪពុក....................................៧៣
ព្រះសាស្តាប្រជុំជាតក.........................................................៧៤

# ជំពូកទី ១

## កំណើតព្រះចន្ទកុមារ

### និទានខាងដើម

*កាលព្រះសាស្តាគង់លើភ្នំគិជ្ឈកូដ ទ្រង់បានប្រារព្ធភិក្ខុទេវទត្ត ហើយសម្តែងនូវធម្មទេសនានេះ មានពាក្យថា "**រាជាសិ លុទ្ទកម្មោ**" ដូច្នេះជាដើម ។*

### ឧបាយទេវទត្តធ្វើឃាតព្រះសាស្តា

*ដំណើររឿងរបស់ភិក្ខុទេវទត្តនោះ ក៏មាននិទានទុកក្នុងគម្ពីរសង្ឃ-ភេទកក្ខន្ធក:ដែរ ។ អ្នកសិក្សា គប្បីអានឲ្យបានជ្រាបតាមសេចក្តីនៃរឿងក្នុងគម្ពីរនោះ តាំងអំពីទេវទត្តបួស រហូតដល់ការចូលទិវង្គតរបស់ព្រះបាទពិម្ពិសារផងចុះ ។ ក្រោយពេលបញ្ជាឲ្យព្រះបាទអជាតសត្តុធ្វើគត់ស្តេចពិម្ពិសារ បានសម្រេចហើយ ភិក្ខុទេវទត្តបានពោលនឹងព្រះបាទអជាតសត្តុថា ៖*

*"បពិត្រមហារាជ គោលបំណងរបស់ព្រះអង្គ បានសម្រេចហើយ ឯគោលបំណងរបស់អាត្មាវិញ នៅពុំទាន់បានសម្រេចនៅឡើយទេ" ។*

*ស្តេចអជាតសត្តុ ត្រាស់សួរ ៖*

"បពិត្រលោកម្ចាស់ ចុះគោលបំណងរបស់លោកម្ចាស់ ដូចម្ដេច?"

ភិក្ខុទេវទត្តតបថា ៖

"ចុះក្រែងអាត្មាធ្វើឃាតព្រះសម្មាសម្ពុទ្ធហើយ ខ្លួនអាត្មានឹងបាន ឡើងតំណែងជាព្រះពុទ្ធនោះអី មិនអ៊ីចឹង" ។

ស្ដេចអជាតសត្តុថា ៖

"ចុះក្នុងរឿងនោះ យើងត្រូវធ្វើដូចម្ដេច?"

ភិក្ខុទេវទត្តតបថា ៖

"បពិត្រមហារាជ ជាចាំបាច់ យើងត្រូវប្រជុំពួកខ្មាន់ធ្នូទាំងអស់" ។

"ប្រពៃណាស់ លោកម្ចាស់" ស្ដេចអជាតសត្តុ យល់ព្រម ។

អជាតសត្តុរាជ កោះប្រជុំពួកខ្មាន់ធ្នូជំនាញបាញ់ចំនួន ៥០០ នាក់ឲ្យមកជួបជុំគ្នា រួចជ្រើសយក ៣១ នាក់ អំពីចំនួន ៥០០ នោះ បញ្ជូនទៅកាន់សម្នាក់របស់ភិក្ខុទេវទត្ត ។ ភិក្ខុទេវទត្ត ហៅមេខ្មាន់ធ្នូម្នាក់មកប្រាប់ថា "ម្នាលនាយ សមណគោតមកំពុងគង់នៅលើភ្នំគិជ្ឈកូដ តែងចង្រ្កមនៅលើទីសម្រាកក្នុងពេលថ្ងៃ អ្នកចូរទៅទីនោះបាញ់ព្រះអង្គដោយព្រួញពិស ឲ្យក្ស័យព្រះជន្ម ហើយចូរមកតាមផ្លូវនេះ" ប្រាប់ដូច្នេះហើយ ភិក្ខុទេវទត្ត បានឲ្យខ្មាន់ធ្នូពីរនាក់ឈរនៅចាំក្នុងផ្លូវនោះ ហើយប្រាប់ថា "បុរសម្នាក់ នឹងមកតាមផ្លូវដែលពួកអ្នកឈរចាំនេះ ពួកអ្នកចូរ

ផ្តាច់ជីវិតគេ ហើយដើរមកតាមផ្លូវនេះ" ហើយឲ្យបុរស ៤ នាក់ឈរចាំលើផ្លូវនោះ និងប្រាប់ថា "បុរសពីរនាក់ នឹងមកតាមផ្លូវដែលពួកអ្នកឈរចាំនេះ ពួកអ្នកចូរផ្តាច់ជីវិតពួកគេ ហើយដើរមកតាមផ្លូវនេះ" ហើយឲ្យមនុស្ស ៨ នាក់ឈរចាំលើផ្លូវនោះ រួចប្រាប់ថា "បុរស ៤ នាក់ នឹងមកតាមផ្លូវដែលពួកអ្នកឈរចាំនេះ ពួកអ្នកចូរផ្តាច់ជីវិតពួកគេ ហើយដើរមកតាមផ្លូវនេះ" ហើយឲ្យមនុស្ស ១៦ នាក់ឈរចាំលើផ្លូវនោះ ដោយប្រាប់ថា "បុរស ៨ នាក់ នឹងមកតាមផ្លូវដែលពួកអ្នកឈរចាំនេះ ពួកអ្នកចូរផ្តាច់ជីវិតពួកគេ ហើយដើរមកតាមផ្លូវនេះ" ។

## កំណត់សម្គាល់

*សំណួរ ៖ "ចុះទេវទត្ត ធ្វើយ៉ាងនេះ ព្រោះហេតុអ្វី ?"*
*ចម្លើយ ៖ "ដើម្បីបិទបាំងនូវអំពើអាក្រក់របស់ខ្លួន" ។*

## ព្រះសាស្តាប្រោសជីវិតពួកខ្មាន់ធ្នូ

គ្រានោះ មេខ្មាន់ធ្នូនោះស្ពាយដាវខាងឆ្វេង ស្ពាយបំពង់ព្រួញខាងក្រោយ កាន់ធ្នូធំឈ្មោះមេណ្ឌសិង្គៈ ដើរឆ្ពោះទៅកាន់សម្នាក់របស់ព្រះតថាគត ដាក់ព្រួញត្រង់ខ្សែបន្ទោះ ឃឹតធ្នូតម្រង់ទៅរកព្រះអង្គ ក្នុងគំនិតថា "អញនឹងបាញ់ព្រះអង្គ" ប៉ុន្តែ ខ្សែធ្នូនៅជាប់គាំង មិនអាចលែងគ្រាប់ព្រួញឲ្យទៅមុខបានឡើយ ។ គាត់រកដាក់ធ្នូចុះ ក៏ដាក់មិនបាន ឈរនៅរមួលខ្លួនស្ទើរបាក់ឆ្អឹងជំនីរ ទាំងមានទឹកមាត់ហៀរឡើក

ឡោក ហត់គឃូស[១]អស់កម្លាំង ទឹកមុខឡើងស្លេក ខ្លួនប្រាណទាំងមូល ក៏ប្រែខ្មៅទៅជារឹងកំព្រឹស ដូចអាការត្រូវម៉ាស៊ីនគាប ។ គាត់ត្រូវមរណ-ភ័យ គំរាមឲ្យស្រយុតស្រយង់ចិត្ត គាំងអស់ខ្លួនប្រាណ អស់ក្តីសង្ឃឹម ។ គ្រានោះ ព្រះសាស្តាទតព្រះនេត្រឃើញបុរសនោះ ទ្រង់បញ្ចេញសូរសៀងដ៏ពីរោះថា ៖

"កុំខ្លាចឡើយ បុរសដ៏ចម្រើន ! ចូរអ្នកចូលមកចុះ" ។

ទើបមេខ្មាន់ធ្នូ អាចដាក់ចុះនូវអាវុធទាំងនោះបាន ភ្លាមនោះ គាត់ក៏ក្រាបចុះទៀបព្រះបាទទាំងគូរបស់ព្រះមានព្រះភាគ និងបានសូមខមាទោសថា ៖

"បពិត្រព្រះអង្គដ៏ចម្រើន ទោសរបស់ខ្ញុំព្រះអង្គបានកន្លងទៅហើយ ព្រោះខ្លួនល្ងង់ខ្លៅ ព្រោះខ្លួនវង្វេង ព្រោះអកុសលគ្របសង្កត់, ខ្ញុំព្រះអង្គមិនដឹងគុណទាំងឡាយរបស់ព្រះអង្គ មកនេះក្នុងគោលបំណងផ្តាច់ព្រះជន្មព្រះអង្គ ដោយតាមបញ្ជារបស់ភិក្ខុទេវទត្ត ដែលជាមនុស្សអន្ធពាល សូមទ្រង់មេត្តាអត់នូវទោសដល់ខ្ញុំព្រះអង្គផង" ។

និយាយដូច្នេះហើយ គាត់អង្គុយក្នុងទីសមគួរ ។ គ្រានោះ ព្រះសាស្តា

[១] (ឱ.) សូរព្យូស ៗ ច្រើនដង ។

សម្ដែងធម៌ ប្រកាសនូវអរិយសច្ចៈ ៤ ធ្វើឲ្យមេខ្នាន់ធ្នូនោះបានសម្រេចសោតាបត្តិផល រួចត្រាស់បង្គាប់ថា ៖

"ម្នាលអ្នកមានអាយុ អ្នកកុំដើរតាមផ្លូវដែលទេវទត្តប្រាប់អី ចូរទៅតាមផ្លូវផ្សេងវិញចុះ" ។

លុះត្រាស់ដូច្នេះហើយ ព្រះសាស្ដាយាងចុះចាកទីចង្រ្កម ប្រថាប់គង់ទៀបគល់ឈើមួយ ។

គ្រានោះ ខ្មាន់ធ្នូពីរនាក់ផ្សេងទៀតពេលមិនឃើញនាយខ្មាន់ធ្នូមកក៏គិតថា "ម៉េចក៏យូរម្ល៉េះ" ក៏ដើរតាមផ្លូវបញ្ច្រាសទៅ ឃើញព្រះទសពល[២] បានចូលទៅរក ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ ។ ព្រះសាស្ដាសម្ដែងនូវធម៌ដល់ពួកគេ ប្រកាសនូវសច្ចៈទាំង ៤ ធ្វើឲ្យពួកគេបានសម្រេចសោតាបត្តិផល រួចទ្រង់ត្រាស់បង្គាប់ថា ៖

"ម្នាលអ្នកមានអាយុ អ្នកកុំដើរតាមផ្លូវដែលទេវទត្តប្រាប់អី ចូរទៅតាមផ្លូវនេះវិញ" ។

សូម្បីពួកខ្មាន់ធ្នូឯទៀត ៗ ក៏បានមកអង្គុយស្ដាប់ព្រះធម៌ទេសនារបស់

---

[២] គុ. ឬ ន. (បា.) ដែលមានកម្លាំង ១០ គឺមានកម្លាំងស្មើនឹងដំរីវិសេស ១០ (ព្រះសម្មាសម្ពុទ្ធ) : ព្រះទសពល ។

ព្រះសាស្តា ហើយបានសម្រេចសោតាបត្តិផល រួចនាំគ្នាទៅតាមផ្លូវផ្សេង ៗ ដោយឧបាយដូច្នោះដែរ ។ គ្រានោះ មេខ្មាន់ធ្នូដែលមកមុនគេបានចូលទៅរកភិក្ខុទេវទត្ត ពិតថេរដីកា[៣]ថា ៖

"បពិត្រទេវទត្តដ៏ចម្រើន ខ្ញុំព្រះករុណា មិនអាចផ្តាច់ព្រះជន្មព្រះសម្មាសម្ពុទ្ធបានទេ ដ្បិតព្រះមានព្រះភាគអង្គនោះ មានឫទ្ធិច្រើន មានអានុភាពខ្លាំង" ។

ខ្មាន់ធ្នូទាំងអស់នោះ គិតថា "យើងបានជីវិត ព្រោះអាស្រ័យព្រះសម្មាសម្ពុទ្ធ" ដូច្នេះ ពួកគេនាំគ្នាបួសក្នុងសម្នាក់ព្រះសាស្តា ហើយបានសម្រេចព្រះអរហត្តផលគ្រប់ ៗ អង្គទៀតផង ។

## មូលហេតុនៃនិទាន

ដំណឹងនេះ បានលេចឮល្បីល្បាញទៅដល់ពួកភិក្ខុ ។ ភិក្ខុទាំងឡាយ ផ្តើមសន្ទនាគ្នាក្នុងសាលាធម្មសភាថា ៖

"ម្នាលលោកមានអាយុ ឮដំណឹងមកថា ភិក្ខុទេវទត្ត បានព្យាយាមដើម្បីផ្តាច់ជីវិតជនជាច្រើននាក់ ដោយសារចិត្តចងពៀរចំពោះព្រះតថាគតមួយអង្គ ជនទាំងឡាយនោះ រួចផុតពីសេចក្តីស្លាប់

---

[៣] (កិ.) (ស. ស.) (ប្រ. និ. ពឹត) ប្រាប់, ឲ្យដំណឹង, ទូល (ប្រាប់តាមពិត) : ពិតថេរដីកា, ចាំពិតលោកគ្រូសិន, សូមពិតមក...។ **ពិតទូល** ឬ **ទូលពិត** ទូលឲ្យជ្រាបសេចក្តីពិត ។

គ្រប់ ៗ គ្នា ព្រោះអាស្រ័យព្រះបរមសាស្តា" ។

គ្រានោះ ព្រះសាស្តាយាងមក ត្រាស់សួរថា ៖

"ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ អ្នកទាំងឡាយប្រជុំគ្នាសន្ទនាពីរឿងអ្វី ?"

ក្រោយពេលភិក្ខុទាំងឡាយក្រាបទូលរឿងនោះឲ្យទ្រង់បានជ្រាបហើយ ព្រះសាស្តា ទ្រង់ត្រាស់ថា ៖

"ម្នាលភិក្ខុទាំងឡាយ មិនមែនទើបតែពេលនេះទេ សូម្បីពីអតីតជាតិ ក៏ទេវទត្តបានព្យាយាម ដើម្បីផ្តាច់ជីវិតជនជាច្រើននាក់ ដោយសារចិត្តចងពៀរចំពោះតថាគតតែម្នាក់អ៊ីចឹងដែរ" ។

ភិក្ខុទាំងឡាយ ក្រាបទូលអារាធនាឲ្យទ្រង់នាំអតីតនិទាននោះ មកតំណាល ដែលមានដំណើររឿងដូចតទៅនេះ ៖

## ចន្ទកុមារកាត់ក្តីយុត្តិធម៌

ក្នុងអតីតកាល ក្រុងពារាណសីនេះ មានឈ្មោះថា **បុប្ផវតី** ។ ស្តេចក្នុងក្រុងបុប្ផវតីនោះ ព្រះនាមថា **វសវត្តី** ។ បុត្ររបស់ស្តេចវសវត្តីនោះ ព្រះនាមថា **ឯករាជ** បានសោយរាជ្យស្នងព្រះបិតា ។ បុត្ររបស់ស្តេចឯករាជនោះ ព្រះនាមថា **ចន្ទកុមារ** មានឋានៈជាឧបរាជ ។ ព្រាហ្មណ៍

ឈ្មោះ **ខណ្ឌហាល** ជាបុរោហិត ។ គាត់ជាព្រះរាជគ្រូ បង្រៀនអត្ថនិង ធម៌ដល់ព្រះរាជា ។ ពុថា ព្រះរាជាបានចាត់ទុកគាត់ថាជាបណ្ឌិត ដូច្នេះទ្រង់ក៏តែងតាំងគាត់ជាអ្នកវិនិច្ឆ័យក្តី ។ ខណ្ឌហាលព្រាហ្មណ៍ នោះជាមនុស្សលោភ តែងតែទទួលសំណូក ហើយធ្វើអ្នកមិនមែនជា ម្ចាស់របស់ឲ្យជាម្ចាស់របស់ អ្នកដែលជាម្ចាស់របស់ឲ្យជាអ្នកមិនមែនជា ម្ចាស់របស់ ។ លុះតមកក្នុងថ្ងៃមួយ មានបុរសចាញ់ក្តីម្នាក់ បានដេរ ហើយ ដើរចេញអំពីសាលាក្តី គាប់ចួនពេលនោះជួបចន្ទកុមារដែល កំពុងយាងមកកាន់ទីរាជុបដ្ឋាន[៤] គេក៏ស្ទុះទៅក្រាបចុះទៀបព្រះបាទ ទាំងគូរបស់ព្រះអង្គ ហើយយំ ។ ចន្ទកុមារសួរ ៖

"នែបុរសដ៏ចម្រើន មានរឿងហេតុអ្វី ទើបអ្នកយំ ?"

បុរសចាញ់ក្តីទូលថា ៖

"បពិត្រព្រះរាជបុត្រ ខណ្ឌហាលព្រាហ្មណ៍តែងកាត់ក្តីស៊ីសំណូក ក្នុងសាលាក្តី គាត់ទទួលសំណូកហើយ កាត់ក្តីឲ្យទូលបង្គំចាញ់" ។

"កុំខ្លាចឡើយ" ចន្ទកុមារលួងលោមគាត់ ហើយបាននាំគាត់ទៅ កាន់សាលាក្តី ធ្វើម្ចាស់ឲ្យជាម្ចាស់ មិនមែនម្ចាស់ឲ្យជាអ្នកមិនមែន ម្ចាស់ ប្រកបដោយយុត្តិធម៌ ។ មហាជន បានថ្វាយសព្ទសាធុការពរ

---

[៤] ការបម្រើ, ការទំនុកបម្រុងព្រះរាជា ។

ដោយសំឡេងខ្លាំង ៗ ។ ព្រះរាជាឮស្នូរនោះ ទ្រង់សួរ "សំឡេងអ្វីហ្នឹង ?" លុះឮដំណឹងថា "ចន្ទកុមារបានវិនិច្ឆ័យរឿងក្ដីត្រឹមត្រូវ ទុំះជាសព្ទសាធុការពរអបអរសាទរចំពោះព្រះចន្ទកុមារ" ដូច្នេះ ព្រះរាជាមានអំណរជាខ្លាំង ។ ព្រះកុមារយាងមកដល់ ថ្វាយបង្គំព្រះអង្គ ហើយប្រថាប់គង់ក្នុងទីសមគួរ ។ ព្រះរាជាសួរថា ៖

"នែបា ឮថាអ្នកបានវិនិច្ឆ័យរឿងក្ដីមួយពិតមែនឬ ?"

ព្រះកុមារឆ្លើយ ៖

"ព្រះករុណាថ្លៃវិសេស ពិតមែន" ។

ព្រះរាជាត្រាស់ថា ៖

"បើដូច្នោះ ពីថ្ងៃនេះទៅ អ្នកចូរធ្វើជាអ្នកកាត់ក្ដីចុះ" ។

ត្រាស់ដូច្នេះហើយ ស្ដេចទ្រង់បានប្រទាននូវសាលាក្ដីដល់ចន្ទកុមារ ។

## ព្រះរាជាសុបិនឃើញភពតាវត្តិង្ស

ចាប់តាំងពីពេលនោះមក ខណ្ឌហាលព្រាហ្មណ៍ លែងបានទទួលសំណូក ដាច់កម្រៃ ក៏បានចងអាឃាតចំពោះព្រះកុមារ តាំងពីគ្រានោះមក តែងរកឱកាសចាប់ទោសកំហុសរបស់ព្រះកុមារ ។ រីឯព្រះបាទឯករាជអង្គនេះ ជាក្សត្រិយ៍មានបញ្ញាខ្សោយ ។ ថ្ងៃមួយ ក្នុងពេលរាត្រីជិតភ្លឺ ព្រះរាជាអង្គនោះ ទ្រង់សុបិនឃើញភពតាវត្តិង្ស មានខ្លោងទ្វារ

ប្រដាប់ដោយក្បូរក្បាច់រចនា កំពែងជាវិការៈនៃកែវ ៧ ប្រការ មហាវិថី ខ្សាច់មាសវែងចម្ងាយ ៦០ យោជន៍ ប្រាសាទវេជយន្ត[៥]កម្ពស់ ១០០០ យោជន៍ ព្រៃនន្ទវ័ននិងស្រះនន្ទាបោក្ខរណី ជាកន្លែងគួរឲ្យរីករាយ ព្រមទាំងមីរដេរដាសដោយពួកទេវតា ។ ស្ដេចតើនហើយ ទ្រង់មាន រាជបំណងចង់ទៅទីនោះ ទើបទ្រង់ព្រះចិន្ដាថា ៖

"ថ្ងៃស្អែក ក្នុងវេលាអាចារ្យខណ្ឌហាលមក អញនឹងសួរបញ្ជាក់ រឿងផ្លូវទៅកាន់ទេវលោក ហើយអញនឹងទៅទេវលោកតាមផ្លូវ ដែលខណ្ឌហាលព្រាហ្មណ៍ប្រាប់" ។

ចំណែកខណ្ឌហាលព្រាហ្មណ៍ ផ្ទួតទឹកពីព្រលឹម ស្រស់ស្រូបអាហារ ពេលព្រឹកហើយមកកាន់ទីរាជុបដ្ឋាន ចូលទៅកាន់រាជនិវេសន៍ សួរនូវ ការផ្ទំជាសុខរបស់ព្រះរាជា ។ គ្រានោះ ព្រះបាទឯករាជ ជាស្ដេចក្នុង ក្រុងបុប្ផវតី ជាអ្នកធ្លាប់មានព្រះទ័យរបឹងរឹងរូស សួររកផ្លូវទៅ ព្រហ្មលោកចំពោះបុរោហិត ឈ្មោះខណ្ឌហាល ជាពូជពង្សព្រហ្ម ជា មនុស្សល្ងង់វង្វេងថា ៖

"សគ្គាន មគ្គមាចិក្ខ ត្វំសិ ព្រាហ្មណ ធម្មវិនយកុសលោ

---

[៥] (ន.) (បា.),(សំ.) (--ជៈយ័ន) (ពេជយន្ត; ពៃជ--) ឈ្មោះប្រាសាទឬរាជរថ កើត សម្រាប់ព្រះឥន្ទ្រ : ប្រាសាទវេជយ័ន្ត, រថវេជយ័ន្ត ។

យថា ឥតោ វជន្តិ សុគតឹ    ឯវា បុញ្ញានិ ករោន្ត៉ាន" ។

"ម្នាលព្រាហ្មណ៍ អ្នកជាមនុស្សឈ្លាសក្នុងសុចរិតធម៌ផង អាចារ-វិន័យផង ចូរអ្នកប្រាប់ផ្លូវសួគ៌ដល់យើង តាមទំនងដែលពួកជនធ្វើបុណ្យទាំងឡាយ ចាកចេញលោកនេះ ហើយទៅកាន់សុគតិដូច្នោះផងចុះ" ។

## ខណ្ឌហាលព្រាហ្មណ៍ប្រាប់អំពីវិធីបូជាយញ្ញ

បញ្ហានេះ ព្រះរាជា គួរណាស់តែសួរព្រះសព្វញ្ញុពុទ្ធឬសាវកទាំងឡាយរបស់ព្រះសព្វញ្ញុពុទ្ធ ថាបើមិនបានអរិយបុគ្គលទាំងនោះទេ គួរណាស់តែសួរពោធិសត្វ ទើបត្រឹមត្រូវ ។ ប៉ុន្តែព្រះរាជា បែរជាសួរខណ្ឌ-ហាលព្រាហ្មណ៍ ជាមនុស្សល្ងង់វង្វេងយ៉ាងនោះទៅវិញ ប្រៀបបាននឹងបុរសវង្វេងផ្លូវ ៧ ថ្ងៃ សួររកផ្លូវប៉ះចំមនុស្សវង្វេងផ្លូវ ១ ខែដូច្នោះដែរ ។ ខណ្ឌហាលព្រាហ្មណ៍ គិតថា ៖

"នេះជាឱកាសល្អ ដើម្បីផ្ចាញ់ផ្ចាលបច្ចាមិត្ររបស់អញហើយ ឥឡូវនេះអញនឹងញុំាងចន្ទកុមារឲ្យក្ស័យជីវិត តាមគោលបំណងរបស់អញ" ។

ហើយក៏ក្រាបទូលព្រះរាជាថា ៖

"អតិទានំ ទទិត្វាន អវជ្ឈេ ទេវ ឃាតេត្វា;
ឯវំ វជន្តិ សុគតឹ ទេ ហ បុញ្ញានិ កត្វាន" ។

"បពិត្រព្រះសម្មតិទេព ពួកជនធ្វើបុណ្យទាំងឡាយ កាលនឹងទៅកាន់ឋានសួគ៌ តែងឲ្យទានដ៏ក្រៃលែង សម្លាប់បុគ្គលដែលមិនគួរសម្លាប់ទាំងឡាយ ហើយទៅកាន់សុគតិយ៉ាងនេះ ។ ប្រសិនបើព្រះអង្គមានបំណងទៅកាន់ឋានសួគ៌ សូមព្រះអង្គធ្វើយ៉ាងនោះដែរចុះ ក្រាបទូល" ។

គ្រានោះ ព្រះរាជាសួរបញ្ជាក់សេចក្ដីនឹងខណ្ឌហាលថា ៖

"កឹ បន តំ អតិទានំ កេ ច អវជ្ឈា ឥមស្មឹ លោកស្មឹ
ឯតញ្ច ខោ នោ អក្ខាហិ យជិស្សាមិ ទទាមិ ទានានិ" ។

"ទានដ៏ក្រៃលែងនុ៎ះ តើដូចម្ដេច ? ក្នុងលោកនេះ បុគ្គលទាំងឡាយដូចម្ដេច ដែលមិនគួរសម្លាប់ ? ចូរអ្នកប្រាប់សេចក្ដីនោះដល់យើង យើងនឹងបូជានិងឲ្យទានទាំងឡាយ" ។

ខណ្ឌហាលព្រាហ្មណ៍ រៀបរាប់ពន្យល់ទូលដូច្នេះថា ៖

"បុត្តេហិ ទេវ យជិតព្វំ មហេសីហិ នេគមេហិ ច
ឧសភេហិ អាជានិយេហិ ចតូហិ សព្វចតុក្កេន

ទេវ យជិតព្វំ"។

"បពិត្រព្រះសម្មតិទេព ព្រះអង្គគប្បីបូជា ដោយព្រះរាជបុត្រទាំងឡាយផង ដោយព្រះអគ្គមហេសីទាំងឡាយផង ដោយអ្នកនិគមនិងពួកសេដ្ឋីទាំងឡាយផង ។ បពិត្រព្រះសម្មតិទេព ព្រះអង្គគប្បីបូជា ដោយគោឧសភនិងសេះអាជានេយ្យ ដោយសត្វបួន ៗ ទាំងអស់ ។ ជាការពិតណាស់ ព្រះរាជាទាំងឡាយ លុះកាត់ក្បាលជនទាំងនោះ ដោយព្រះខាន់ ត្រងយកឈាមដែលចេញពីបំពង់កចាក់ក្នុងរណ្ដៅបូជាយញ្ញរួច មុខជានឹងទៅកាន់ទេវលោកទាំងរស់ ។ បពិត្រមហារាជ ការឲ្យបាយទឹកជាគ្រឿងបំបាត់គម្លាននិងសម្រេក ដល់សមណព្រាហ្មណ៍ ក្មេងកំព្រា អ្នកដំណើរ ថ្មើរព្រៃនិងស្មូមយាចកទាំងឡាយ បានឈ្មោះថា "ត្រឹមតែជាទានធម្មតាប៉ុណ្ណោះ" ។ ឯការសម្លាប់បុត្រាបុត្រីជាដើមនេះ ហើយយកឈាមដែលចេញពីបំពង់ករបស់ពួកគេមកបូជាយញ្ញ ទើបឈ្មោះថាជា "**អតិទាន**[៦]" ។

ព្រះរាជាត្រាស់សួរផ្លូវទៅកាន់ទេវលោកឯណោះទេ តែខណ្ឌហាលព្រាហ្មណ៍ បែរជាព្យាករបញ្ហាឆ្លើយប្រាប់ផ្លូវទៅនរកថ្វាយស្ដេចទៅវិញ ។ តាមការពោលមកនេះ ខណ្ឌហាលព្រាហ្មណ៍ បានដាក់ចន្ទ-

---

៦ អំណោយយ៉ាងធំ, ទានដ៏ប្រសើរក្រៃលែងជាងទានទាំងពួង ។

កុមារចូលក្នុងចំណោមមហាជន ដោយគិតថា ៖

"ប្រសិនបើអញយកតែចន្ទកុមារមួយអង្គឯង ជនទាំងឡាយ នឹងសម្គាល់ថាអញមានចិត្តចង់ពៀរចំពោះព្រះអង្គពុំខាន" ។

និយាយពីជនខាងក្នុងបុរីទាំងអស់ កាលបើបានឮនូវសម្ដីរបស់ស្ដេច និងព្រាហ្មណ៍និយាយដូច្នេះ ម្នាក់ ៗ កាន់តែភ័យភិត គិតព្រួយ កើតទុក្ខទោម្នេញ ថប់បារម្ភ ចំបែងចិត្ត ញ័រចំប្រប់ថប់ក្នុងបេះដូង ស្រែកព្រមគ្នាយ៉ាងខ្លាំង ៗ ។ សំឡេងគឹកកង គួរខ្លាច បានលាន់ឮឡើងរំពងក្នុងរាជវាំង ព្រោះឮព្រះរាជឱង្ការថា ព្រះកុមារទាំងឡាយ និងព្រះអគ្គមហេសីទាំងឡាយ ត្រូវសម្លាប់ ។ រាជត្រកូលទាំងមូល ហាក់ដូចជាព្រៃសាលវ័ន ត្រូវខ្យល់យុគន្ធរបក់បោក ។ ខណ្ឌហាលព្រាហ្មណ៍ក្រាបទូលសួរព្រះរាជាថា ៖

"បពិត្រមហារាជ ចុះព្រះអង្គអាចបូជាយញ្ញឬមិនអាច ?"

ស្ដេចថា ៖

"និយាយថី លោកអាចារ្យ ! យើងនឹងបូជាយញ្ញដើម្បីទៅកាន់ទេវលោក" ។

ខណ្ឌហាលព្រាហ្មណ៍ថា ៖

"ធម្មតា បុគ្គលអ្នកខ្លាច តែងមានអធ្យាស្រ័យខ្សោយ មិនមាន

សមត្ថភាពដើម្បីបូជាយញ្ញបានទេ, សូមព្រះអង្គញុំាងជនទាំង
ពួងឲ្យប្រជុំគ្នាក្នុងទីនេះ រីឯទូលបង្គំនឹងធ្វើកិច្ចការខាងរណ្ដៅ
យញ្ញ" ។

និយាយដូច្នេះហើយ ខណ្ឌហាលព្រាហ្មណ៍យកពួកពលដ៏ល្មមគ្រប់
គ្រាន់របស់ខ្លួនចេញអំពីក្រុង បញ្ជាឲ្យជីករណ្ដៅធ្វើឲ្យមានផ្ទៃរាបស្មើ
រួចហ៊ុមពទ្ធជុំវិញដោយរបង ។

## កំណត់សម្គាល់

សំណួរ ៖ "ហេតុអ្វី បានជាគាត់ធ្វើយ៉ាងហ្នឹង ?"
ចម្លើយ ៖ "ព្រោះថា ព្រាហ្មណ៍បុរាណទាំងឡាយ មុននឹងធ្វើកម្មវិធី
តែងតែធ្វើរបងពទ្ធជុំវិញរណ្ដៅយញ្ញ ដើម្បីចៀសវាងកុំឲ្យ
សមណៈឬព្រាហ្មណ៍ណាមួយ អ្នកប្រកបដោយធម៌ មក
រារាំងបាន" ។

# ជំពូកទី ២

## សំណោកមហាជន

### ព្រះរាជាបញ្ជាឲ្យចាប់ពួករាជបុត្រ

*ចំណែកព្រះរាជាឲ្យគេហៅទាហានចូលមកគាល់ ហើយបញ្ជាថា "នែអស់លោក យើងនឹងសម្លាប់បុត្រាបុត្រីនិងភរិយាទាំងឡាយរបស់ខ្លួន បូជាយញ្ញ ដើម្បីធ្វើជាផ្លូវចម្លងទៅកាន់ទេវលោក ពួកអ្នកចូរទៅនាំខ្លួនពួកគេទាំងអស់មកទីនេះ ភ្លាមមក" រួចទ្រង់បញ្ជាថែមទៀតថា ៖*

"គច្ឆថ វទេថ កុមារេ ចន្ទំ សូរិយញ្ច ភទ្ទសេនញ្ច
សូរញ្ច វាមគោត្តញ្ច បចុរា កិរ ហោថ យញ្ញត្ថាយ" ។

*"អ្នកទាំងឡាយ ចូរទៅប្រាប់រាជកុមារទាំងឡាយ គឺចន្ទកុមារ ១ សុរិយកុមារ ១ ភទ្ទសេនកុមារ ១ សូរកុមារ ១ វាមគោត្តកុមារ ១ ថា អ្នកទាំងឡាយ ចូរមកជួបជុំគ្នាដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ" ។*

*ចន្ទកុមារនិងសុរិយកុមារ ពីរអង្គនេះ ជាបុត្ររបស់អគ្គមហេសីព្រះនាមថា **គោតមិទេវី** ។ ឯភទ្ទសេនកុមារ សូរកុមារ និងវាមគោត្តកុមារ ជាបងប្អូនប្រុសម្តាយទីទៃ ។*

ទាហានទាំងឡាយនោះ ទៅកាន់សម្នាក់របស់ចន្ទកុមារមុនគេ ហើយក្រាបទូលថា ៖

"បពិត្រព្រះកុមារ ព្រោះថាព្រះបិតាព្រះអង្គមានបំណងចង់សម្លាប់ព្រះអង្គ ហើយនឹងទៅកាន់ទេវលោក ព្រះបិតាព្រះអង្គមានបញ្ជាឲ្យខ្ញុំព្រះអង្គមកនាំខ្លួនព្រះកុមារទៅ" ។

ចន្ទកុមារ ៖

"តើព្រះអង្គបានបញ្ជាពួកអ្នកឲ្យមកចាប់ខ្ញុំ តាមពាក្យរបស់អ្នកណា ?"

ទាហាន ៖

"តាមពាក្យរបស់ខណ្ឌហាលព្រាហ្មណ៍ ព្រះកុមារ" ។

ចន្ទកុមារ ៖

"ចុះព្រះបិតាឲ្យពួកអ្នកមកចាប់តែខ្ញុំម្នាក់ឯង ឬចាប់អ្នកផ្សេងដែរ ?"

ទាហាន ៖

"បពិត្រព្រះរាជបុត្រ សូម្បីបុត្រផ្សេង ៗ ក៏ព្រះបិតាព្រះអង្គបង្គាប់ឲ្យចាប់ដែរ, ព្រោះថា ទ្រង់មានបំណងបូជាយញ្ញដោយសត្វមួយមុខបួន ៗ ទាំងអស់ទៀតផង" ។

## ព្រះរាជាបង្គាប់ឲ្យចាប់ពួករាជធីតានិងមហេសី

ចន្ទកុមារនោះ គិតថា "ខណ្ឌហាលព្រាហ្មណ៍ មិនមានពំនៀរជាមួយនឹងជនផ្សេង ៗ ទេ ប៉ុន្តែគេឲ្យព្រះបិតាសម្លាប់មនុស្សសត្វជាច្រើន ព្រោះការចងពៀរចំពោះអញតែម្នាក់គត់ ដ្បិតថាគេលែងបាន ស៊ីសំណូកក្នុងសាលាក្តី ដូច្នេះ ការរំដោះមនុស្សសត្វទាំងអស់នោះ ជាភារៈរបស់អញ កាលបានជួបនឹងព្រះបិតា" ។ ទើបចន្ទកុមារប្រាប់ទាហានទាំងនោះថា "បើអ៊ីចឹងមែន ចូរធ្វើតាមពាក្យរបស់ព្រះបិតាចុះ" ។ ទាហានទាំងឡាយ នាំចន្ទកុមារទៅទុកក្នុងទីសមគួរក្នុងព្រះលានហ្លួង ហើយទៅនាំជនបីនាក់ទៀត មកទុកក្នុងទីជិតចន្ទកុមារស្រេចបាច់ហើយ ទើបទៅរាយការណ៍ថ្វាយព្រះរាជាថា ៖

"បពិត្រព្រះសម្មតិទេព ពួកបុត្ររបស់ព្រះអង្គ ទូលបង្គំបាននាំមកអស់ហើយ" ។

ព្រះរាជាឮពាក្យរបស់ពួកគេហើយ ទ្រង់បង្គាប់ទៀតថា ៖

"នែអស់លោក ឥឡូវនេះ ពួកអ្នកចូរទៅនាំពួកបុត្រីរបស់យើងមក
ទុកផ្តុំគ្នា ជាមួយបងប្អូនប្រុសរបស់ពួកគេទាំងនោះចុះ" ។

រួចត្រាស់បន្តទៀតថា ៖

"កុមារិយោបិ វេទេថ ឧបសេនំ កោកិលញ្ច មុទិតញ្ច
នន្ទញ្ចាបិ កុមារឹ បចុរា ភិរ ហោថ យញ្ញត្ថាយ" ។

“អ្នកទាំងឡាយ ចូរប្រាប់កុមារីទាំងឡាយ គឺកុមារីមានឈ្មោះ ឧបសេនា ១ កោកិលា ១ មុទិតា ១ នន្ទា ១ ថានាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ” ។

ទាហានទាំងឡាយនោះ ក្រាបទូលថា “ពួកទូលបង្គំនឹងធ្វើតាមព្រះរាជ-ឱង្ការ” ហើយក៏នាំគ្នាទៅកាន់សម្នាក់របស់ធីតាទាំងឡាយ រួចនាំពួកនាងដែលកំពុងតែយំយែកខ្សឹកខ្សួល មកនៅផ្តុំគ្នាក្នុងសម្នាក់របស់បងប្អូនប្រុស ។ បន្ទាប់មក ព្រះរាជាបញ្ជាឲ្យគេយកមហេសីទាំងឡាយរបស់ព្រះអង្គមកទៀតថា ៖

“វិជយម្បិ មយ្ហំ មហេសិំ ឯរាវតិំ កេសិនិំសុនន្ទញ្ច
លក្ខណាវរូបបន្នា បចុរា កិរ ហោន្ត យញ្ញត្ថាយ” ។

“អ្នកទាំងឡាយ ចូរប្រាប់មហេសីទាំងឡាយរបស់អញ គឺនាងវិជយា ១ នាងឯរាវតី ១ នាងកេសិនី ១ នាងសុនន្ទា ១ ដែលជាស្ត្រីបរិបូណ៌ដោយលក្ខណៈ ៦៤ ដ៏ប្រសើរថា នាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ” ។

## ព្រះរាជាបង្គាប់ឲ្យចាប់សេដ្ឋី ៤ នាក់

ទាហានទាំងនោះ បាននាំយកពួកនាងដែលកំពុងតែខ្សឹកខ្សួល ទៅទុកនៅផ្តុំគ្នាក្នុងសម្នាក់របស់កុមារកុមារី ។ បន្ទាប់មក ព្រះរាជា

ត្រាស់បញ្ជាឲ្យទៅចាប់សេដ្ឋី ៤ នាក់ មកទៀតថា ៖

"គហបតយោ ច វទេថ បុណ្ណមុខំ ភទ្ទិយំ សិង្គាលញ្ច
វឌ្ឍញ្ចាបិ គហបតិំ បចុរា ភិវ ហោថ យញ្ញត្ថាយ" ។

"អ្នកទាំងឡាយ ចូរប្រាប់គហបតីទាំងឡាយ គឺគហបតីឈ្មោះ បុណ្ណមុខៈ ១ ភទ្ទិយៈ ១ សិង្គាលៈ ១ វឌ្ឍៈ ១ ថា ចូរអ្នកទាំងឡាយ មកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ" ។

រាជបុរសទាំងឡាយ ក៏បានទៅនាំសេដ្ឋីទាំងនោះមកតាមព្រះរាជបញ្ជា ។ ក្នុងកាលដែលស្ដេចចាប់កូនប្រពន្ធដើម្បីបូជាយញ្ញ មនុស្សទូទាំងនគរស្ងាត់ឈឹង គ្មាននរណាមួយហ៊ានហើបមាត់រិះគន់អ្វីមួយម៉ាត់សោះ ។ ប៉ុន្តែត្រកូលសេដ្ឋី គឺជាសម្ពន្ធដ៏សំខាន់មួយក្នុងប្រទេសជាតិ ដូច្នោះហើយ កាលសេដ្ឋីទាំងនោះត្រូវបានចាប់ខ្លួន នគរទាំងមូលមានការជ្រួលច្របល់ រចល់រញ៉ាល់ រដើបរដោរ[៧] ជ្រើមផ្អើល ភ្ញូកភ្ញឹក ច្រាល់រអើល ពព្រើតពព្រាំង[៨] ស្ទុះរត់ឈូឆរមកចោមរោមពួកសេដ្ឋី ដើរទៅកាន់ព្រះបរមរាជវាំងជាមួយនឹងញាតិសន្ដានព្រៀងលានរបស់ពួកគេ ។ គ្រានោះ សេដ្ឋីទាំងឡាយ ដែលមានកូន ប្រពន្ធ និងពួកញាតិ ចោម

---

[៧] ដែលផ្អើលជ្រើមចុះជ្រើមឡើងស៊ើបសួរគ្នាឲ្យដឹងការណ៍ពិត : ផ្អើលរដើបរដោរ ។

[៨] ដែលស្ទុះស្ទាឆ្វេឆ្វាងើបងើយព្រើត ៗ រឿយ ៗ ។

ពោមជួបជុំគ្នាដេរដាសក្នុងទីនោះ ពួកគេបានថ្វាយបង្គំព្រះរាជា អង្វរសូមនូវជីវិតរៀង ៗ ខ្លួនថា ៖

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គធ្វើពួកទូលបង្គំឲ្យមានភក់លើក្បាល[៩] ដាក់ឲ្យធ្វើជាខ្ញុំបម្រើរបស់ព្រះអង្គ ពួកទូលបង្គំនឹងធ្វើកិច្ចទាំងអស់នោះដើម្បីបម្រើថ្វាយព្រះអង្គ ពុំនោះសោត[១០] កាលបើព្រះអង្គ មិនជឿពួកទូលបង្គំទេ សូមព្រះអង្គញ៉ាំងទាហានទាំងអស់ឲ្យប្រជុំគ្នា ប្រកាសពួកទូលបង្គំជាទាសៈ ក្នុងទ្រព្យសម្បត្តិពាក់កណ្ដាល ពួកទូលបង្គំ ព្រមទទួលនូវភាពជាទាសៈរបស់ព្រះអង្គ" ។

បើទោះណាជាពួកគេអង្វរយ៉ាងនេះក៏ដោយ ក៏គ្មាននរណាមួយ បានអនុញ្ញាតឲ្យដោះលែងទៅវិញដែរ ។ ពួកទាហានចាប់ទាញមនុស្ស

---

[៩] ពាក្យប្រៀបទៅនឹងមនុស្សមានឋានៈតូចទាប ធ្វើការជាទាសៈ មានភក់ជ្រាំប្រឡាក់ក្បាល ខ្លួនប្រាណ ហើយមិនប្រកាន់ ។

[១០] (និ.) មួយទៀត, មួយវិញទៀត, មួយវិញសោត, បើមិនដូច្នោះ ។ ពាក្យនិបាតជាសន្ធានសម្រាប់ប្រើតសង្កត់សេចក្ដីបន្ទាប់អំពីពាក្យ ឬ, ឬក៏, ឬថា; ប្រើរៀងបន្តគ្នាតាមលំដាប់មុនក្រោយគឺពាក្យ ឬ ត្រូវរៀងមុន, ឬក៏ រៀងត្រង់ទី ២, ពុំនោះ ត្រង់ទី ៣, ពុំនោះសោតត្រង់ទី ៤ : ត្រូវចាត់បម្រើឲ្យទៅប្រាប់, ឬផ្ដាំផ្ញើនឹងមនុស្សអ្នកទៅមក, ឬក៏សរសេរសំបុត្រឲ្យបម្រើយកទៅ, ពុំនោះផ្ញើនឹងគេអ្នកទៅមក, ពុំនោះសោតបិទតែមប្រៃផ្ញើតាមប្រៃសណីយ៍ក៏បាន ។

ផ្សេង ៗ ឲ្យថយចេញ ហើយចាប់សេដ្ឋីទាំងនោះយកទៅឲ្យអង្គុយផ្ទុំគ្នា ក្នុងសម្នាក់របស់ព្រះកុមារ ។ បន្ទាប់មក ព្រះរាជាចេញបញ្ជាឲ្យទៅ ចាប់ដំរីជាដើម យ៉ាងនេះថា ៖

"អភយង្ករម្បិ មេ ហត្ថឹ　　នាឡាគិរឹ អច្ចុគ្គតំ វរុណទន្តំ
អានេថ ខោ នេ ខិប្បំ　　យញ្ញត្ថាយ ភវិស្សន្តិ ។
អស្សរតនម្បិ កេសឹ　　សុរាមុខំ បុណ្ណកំ វិនតកញ្ច
អានេថ ខោ នេ ខិប្បំ　　យញ្ញត្ថាយ ភវិស្សន្តិ ។
ឧសភម្បិ យូថបតឹ អនោជំ និសភំ គវម្បតឹ តេបិ មយ្ហំ អានេថ
សមូហ ករោន្តុ សព្វំ　　យជិស្សាមិ ទទាមិ ទានានិ ។
សព្វំ បដិយាទេថ　　យញ្ញំ បន ឧគ្គតម្ហិ សុរិយម្ហិ
អាណាបេថ ច កុមារេ　　អភិរមន្តុ ឥមំ រត្តឹ ។
សព្វំ ឧបដ្ឋបេថ　　យញ្ញំ បន ឧគ្គតម្ហិ សុរិយម្ហិ
វទេថ ទានិ កុមារេ　　អជ្ជ ខោ បច្ឆិមា រត្តិ" ។

"អ្នកទាំងឡាយ ចូរនាំមកនូវដំរីរបស់យើងឈ្មោះអភយង្ករៈ ១ , នាឡាគិរី ១ អច្ចុគ្គតៈ ១ វរុណទន្តៈ ១ ដំរីទាំងឡាយនោះ នឹងជា សត្វ ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញយ៉ាងឆាប់ ។ អ្នកទាំង ឡាយ ចូរនាំមកនូវសេះកែវរបស់យើង គឺសេះឈ្មោះកេសី ១ សុរាមុខៈ ១ បុណ្ណកៈ ១ វិនតកៈ ១ សេះទាំងឡាយនោះ នឹងជា

សត្វ ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញយ៉ាងឆាប់ ។ អ្នកទាំងឡាយ ចូរនាំយកគោឧសភៈ[១១] ទាំងនោះរបស់យើង គឺគោឧសភៈឈ្មោះយូតបតិ ១ អនោជៈ ១ និសភៈ ១ គវម្បតិ ១ មកឲ្យយើង ។ ជនទាំងឡាយ ចូរធ្វើកិច្ចទាំងពួង ក្នុងទីចំពោះមុខយើង នឹងបូជានិងឲ្យទានទាំងឡាយ ។ អ្នកទាំងឡាយ ចូរតាក់តែងគ្រឿងបូជាគ្រប់មុខ កាលបើព្រះអាទិត្យរះឡើងហើយ យើងនឹងបូជា ។ អ្នកទាំងឡាយ ចូរប្រាប់ពួកកុមារមានចន្ទកុមារជាដើមថា កុមារទាំងឡាយ ចូររីករាយអស់ ១ យប់នេះចុះ ។ អ្នកទាំងឡាយ ចូរតម្កល់ទុកនូវគ្រឿងយញ្ញគ្រប់មុខ កាលបើព្រះអាទិត្យរះឡើង អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់កុមារទាំងឡាយក្នុងកាលឥឡូវនេះថា រាត្រីថ្ងៃនេះឯង ជារាត្រីចុងក្រោយបំផុត" ។

## ព្រះរាជមាតាបិតាអង្វរព្រះរាជា

ព្រះមាតាបិតារបស់ព្រះរាជា គង់ព្រះជន្មនៅឡើយ ។ គ្រានោះអាមាត្យទាំងឡាយរបស់ចន្ទកុមារ ទៅរាយការណ៍ដល់ព្រះរាជមាតាថា "បពិត្រព្រះម៉ែម្ចាស់ បុត្ររបស់ព្រះនាងទ្រង់មានបំណងសម្លាប់បុត្រមហេសី ដើម្បីបូជាយញ្ញ" ។ ព្រះរាជមាតានៃព្រះបាទឯករាជ ទ្រង់ព្រះ

---

[១១] (ន.) (បា.) (អ៊ុសប់) (ឧសភ; សំ. ឫឞភ) គោឈ្មោល, គោឡើងក, គោបា (ច្រើននិយាយថា គោឧសភ) ។

កន្សែងសោយសោក រួចស្ដេចយាងមកអំពីវិមាន[១២] ទ្រង់មានព្រះសវនីយ៍[១៣]សួរនូវសេចក្ដីនោះ នឹងព្រះរាជាថា ៖

"នែបុត្រ ឮថាបុត្រឯងនឹងបូជាយញ្ញ ដោយព្រះរាជបុត្រទាំង ៤ អង្គមែនឬ ?"

ស្ដេចឯករាជឆ្លើយថា ៖

"សព្វេបិ មយ្ហំ បុត្តា ចត្តា    ចន្ទស្មិំ ហញ្ញមានស្មិំ
បុត្តេហិ យញ្ញំ យជិត្វាន    សុគតិំ សគ្គំ គមិស្សាមិ" ។

"កាលបើខ្ញុំសម្លាប់ចន្ទកុមារបូជាហើយ បុត្រទាំងអស់របស់ខ្ញុំ ក៏ខ្ញុំលះបង់ដើម្បីបូជាយញ្ញដែរ លុះខ្ញុំបូជាដោយបុត្រទាំងឡាយហើយ ខ្ញុំនឹងទៅកាន់សុគតិសួគ៌[១៤]" ។

---

[១២] (ន.) (សំ.),(បា.) (ពិមាន) លំនៅ ឬយានជំនិះដ៏ល្អវិសេសសម្រាប់ទេវតា, លំនៅទេវតា ។ ព. ប្រ. ប្រាសាទ, ដំណាក់ ដែលល្អវិសេស សម្រាប់ព្រះមហាក្សត្រ ក៏ហៅពិមាន ដែរ, ដូចយ៉ាង ពិមានអាកាស ជាដើម ។

[១៣] (គុ.) (បា.),(សំ.) (សៈវ៉ៈនី) (សវនីយ; គ្រវណីយ) ដែលគួរស្ដាប់, ដែលត្រូវស្ដាប់ ។ ន. សម្ដីដែលគួរឬត្រូវស្ដាប់ ។ ខ្មែរប្រើជា រ. ស. ចំពោះតែព្រះបន្ទូលរបស់សម្ដេចព្រះវររាជជននី ឬសម្ដេចព្រះអគ្គមហេសី, សម្ដេចព្រះមហាក្សត្រិយានី : ទទួលព្រះសវនីយ៍ ។

គ្រានោះ ព្រះរាជមាតាពន្យល់បុត្រថា ៖

"មា តំ បុត្ត សទ្ទហេសិ សុគតិ កិរ ហោតិ បុត្តយញ្ញេន
និរយានេសោ មគ្គោ នេសោ មគ្គោ ហិ សគ្គានំ ។
ទានានិ ទេហិ កោណ្ឌញ្ញ អហិំសា សព្វភូតភព្យានំ
ឯស មគ្គោ សុគតិយា ន ច មគ្គោ បុត្តយញ្ញេន" ។

*"ម្នាលបុត្រ អ្នកកុំជឿខណ្ឌហាលព្រាហ្មណ៍នោះថា សុគតិបាន ដោយការបូជាបុត្រឲ្យសោះ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរក មិនមែន ជាផ្លូវទៅកាន់ឋានសួគ៌ទេ ។ ម្នាលបុត្រ កោណ្ឌញ្ញគោត្រ ចូរអ្នក ឲ្យទានទាំងឡាយ កុំបៀតបៀនសព្វសត្វដែលកើតហើយនិងសត្វ ត្រូវកើតឡើយ នោះទើបជាផ្លូវនៃសុគតិសួគ៌យ៉ាងពិតប្រាកដ ផ្លូវ សុគតិ មិនមែនបានមកពីការបូជាបុត្រទេ" ។*

*ស្តេចឯករាជក្រាបទូលតបថា ៖*

"អាចរិយានំ វចនា យាតេស្សំ ចន្ទញ្ច សូរិយញ្ច
បុត្តេហិ យញ្ញំ យជិត្វាន ទុច្ចជេហិ សុគតិំ សគ្គំ គមិស្សាមិ" ។

---

[១៤] (ន.) (សំ.),(បា.) (--គៈតិ) *ដំណើរល្អ, ការទៅដោយល្អ (ចំពោះការស្លាប់កើត); ការ ប្រព្រឹត្តត្រូវផ្លូវ, ត្រូវគន្លងធម៌; គន្លងឬលំអានយុត្តិធម៌ ។* (បា.) *ឋានសួគ៌ : ស្លាប់ទៅ កើតក្នុងសុគតិ ។*

*"ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផងតាមពាក្យខណ្ឌហាល អាចារ្យប្រាប់ ការបូជាបុត្រទាំងឡាយដែលគេលះបង់បានដោយកម្រ នឹងបានទៅកាន់សុគតិសួគ៌" ។*

*គ្រានោះ ព្រះរាជមាតារបស់ស្តេចឯករាជ កាលមិនអាចញុាំងបុត្រឲ្យធ្វើតាមសម្តីរបស់ខ្លួនបាន ព្រះនាងក៏ចៀសចេញទៅ ។ ចំណែកព្រះវសវត្តី ជាព្រះរាជបិតា មកត្រាស់សួរនូវហេតុនោះ ចំពោះព្រះបាទឯករាជ ជាបុត្រកើតអំពីព្រះឱរា[១៥]នោះថា ៖*

*"នែបុត្រ ឮថាអ្នកនឹងបូជាយញ្ញដោយបុត្រទាំង ៤ មែនឬ ?"*

*ស្តេចឯករាជតបថា ៖*

"សព្វេបិ មយ្ហំ បុត្តា ចត្តា    ចន្ទស្មឹ ហញ្ញមានស្មឹ
បុត្តេហិ យញ្ញំ យជិត្វាន    សុគតឹ សគ្គំ គមិស្សាមិ" ។

*"កាលបើខ្ញុំសម្លាប់ចន្ទកុមារបូជាហើយ បុត្រទាំងអស់របស់ខ្ញុំ ក៏*

---

[១៥] (ន.) (បា.) (អ៊ុរ៉ា) (ឧរ; សំ. ឧរស៑) ទ្រូង (ព. កា. ប្រើជា ឱរ ក៏មាន, តាមស្រួលមាត់) : *ហែកូនពុំរា ម្តាយតឹងឱរ ស្ទើរប្រេះសញ្ជែក ត្រូវកូនស្តាប់ម្តាយ កុំឲ្យទឹកភ្នែក- ម្តាយហូរច្រើនពេក ណាកូនមាសម្តាយ ។ រ. ស. ព្រះឧរា ឬព្រះឱរា ។ កាព្យមួយយ៉ាងថា : គេរត់ចោលទៅ ឧរាឯងក្តៅ ឈឺផ្សាឥតស្រាក នៅតែម្នាក់ឯង កណ្តោងលំបាក អញត្រូវសម្រាក ឯណាទៅអើយ ! (អ្ហើយ, កុំថា អឺយ) ។*

ខ្ញុំលះបង់ដើម្បីបូជាយញ្ញដែរ លុះបូជាដោយបុត្រទាំងឡាយ ហើយ ខ្ញុំនឹងទៅកាន់សុគតិសួគ៌" ។

គ្រានោះ ព្រះរាជបិតា ពន្យល់បុត្រថា ៖

"មា តំ បុត្ត សទ្ទហេសិ សុគតិ កិរ ហោតិ បុត្តយញ្ញេ
និរយានេសោ មគ្គោ នេសោ មគ្គោ ហិ សគ្គានំ ។
ទានានិ ទេហិ កោណ្ឌញ្ញ អហឹសា សព្ពភូតភព្យានំ
ឯស មគ្គោ សុគតិយា ន ច មគ្គោ បុត្តយញ្ញេន" ។

"ម្នាលបុត្រ អ្នកកុំជឿខណ្ឌហាលព្រាហ្មណ៍នោះថា សុគតិបាន ដោយការបូជាបុត្រឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរក មិនមែនជាផ្លូវទៅកាន់ឋានសួគ៌ទេ ។ ម្នាលបុត្រ កោណ្ឌញ្ញគោត្រ ចូរអ្នកឲ្យទានទាំងឡាយ កុំបៀតបៀនសព្វសត្វដែលកើតហើយនិងសត្វដែលត្រូវកើតឡើយ នោះទើបជាផ្លូវនៃសុគតិសួគ៌យ៉ាងពិតប្រាកដ ផ្លូវសុគតិ មិនមែនបានដោយការបូជាបុត្រទេ" ។

ស្តេចឯករាជតបថា ៖

"អាចរិយានំ វចនា ឃាតេស្សំ ចន្ទញ្ច សូរិយញ្ច
បុត្តេហិ យញ្ញំ យជិត្វាន ទុច្ចជេហិ សុគតឹ សគ្គំ គមិស្សាមិ" ។

"ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យខណ្ឌហាលអាចារ្យប្រាប់ ការបូជាបុត្រទាំងឡាយ ដែលគេលះបង់បានដោយកម្រ នឹងបានទៅកាន់សុគតិសួគ៌" ។

គ្រានោះ ព្រះរាជបិតាមានបន្ទូលថា ៖

"ធានានិ ទេហិ កោណ្ឌញ្ញ អហឹសា សព្ពភូតភព្យានំ
បុត្តបរិវុតោ តុវំ រដ្ឋំ ជនបទញ្ច ធាលេហិ" ។

"ម្នាលបុត្រកោណ្ឌញ្ញគោត្រ ចូរអ្នកឲ្យទានទាំងឡាយ កុំបៀតបៀនសព្វសត្វដែលកើតហើយនិងសត្វដែលនឹងត្រូវកើតឡើយ អ្នកចូរជាមនុស្សដែលបុត្រទាំងឡាយចោមរោមហើយ រក្សាដែននិងជនបទចុះ" ។

## ចន្ទកុមារអង្វរព្រះបិតា

សូម្បីព្រះរាជបិតានោះ ក៏មិនអាចញ៉ាំងបុត្រឲ្យជឿសម្តីរបស់ខ្លួនបានដែរ ។ គ្រានោះ ចន្ទកុមារគិតថា "ទុក្ខរបស់ជនប៉ុណ្ណោះនេះ កើតឡើងដោយអាស្រ័យអញតែម្នាក់ឯង អញនឹងអង្វរព្រះបិតារបស់អញដើម្បីរំដោះជនមានប្រមាណប៉ុណ្ណោះឲ្យរួចចាកមរណទុក្ខ[១៦]" ។ បន្ទាប់

[១៦] ទុក្ខដែលកើតព្រោះមរណៈ, ទុក្ខដែលមានក្នុងវេលាជិតនឹងស្លាប់ ។

មក ចន្ទកុមារ ក៏បានចរចាជាមួយនឹងព្រះបិតាថា ៖

"មា នោ ទេវ អវធិ    ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ  ហត្ថី អស្សេ ច ចាលេម ។
មា នោ ទេវ អវធិ    ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ  ហត្ថិឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ    ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ  អស្សឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ    ទាសេ នោ ទេហិ ខណ្ឌហាលស្ស
យស្ស ហោន្តិ តវ កាមា    អបិ រដ្ឋា បព្ពាជិតា ភិក្ខាចរិយំ
ចរិស្សាម" ។

"បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ពួកទូលបង្គំឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំទាំងឡាយឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកទូលបង្គំទាំងឡាយ សូមជាអ្នកជាប់ចំណងហើយឃ្វាលដំរីនិងសេះ ចោលអាចម៍ដំរីនិងចោលអាចម៍សេះ ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំទាំងឡាយឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ពុំនោះសោត សូមព្រះអង្គបំបរបង់ទូលបង្គំទាំងឡាយចេញចាកដែន ក៏ទូលបង្គំទាំងឡាយ យល់

ព្រមដែរ ក្រាបទូល” ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវការពិលាប[១៧]មានប្រការផ្សេង ៗ របស់ចន្ទកុមារនោះហើយ ទ្រង់ស្ទើរតែបែកហឫទ័យ ទ្រង់ព្រះកន្សែងដោយមាននេត្រាពេញដោយទឹកអស្សុ[១៨] មានព្រះរាជឱង្ការថា ៖

“នរណាមួយ សម្លាប់បុត្រយើងមិនបានឡើយ យើងមិនត្រូវការទេវលោកទេ” ។

រួចទ្រង់ត្រាស់ឲ្យដោះលែងជនទាំងអស់នោះថា ៖

“ទុក្ខំ ខោ មេ ជនយថ វិលបន្តា ជីវិតស្ស កាមា ហិ
មុញ្ចេថ ធានិ កុមារេ អលម្បិ មេ ហោតុ បុត្តយញ្ញេន” ។

“អ្នកទាំងឡាយ ធ្វើឲ្យយើងលំបាកខ្លាំងណាស់ អ្នកទាំងឡាយយំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយលែង

---

[១៧] (ន.) (សំ.),(បា.) (វិលាប) សេចក្ដីខ្សឹកខ្សួលរៀបរាប់, ដំណើរយំបូរបាច់ឮខ្លាំងៗដោយស្ដាយអាល័យ ឬដោយកើតទុក្ខតូចចិត្តណាស់ ។ ខ្មែរច្រើនប្រើជា កិ. ឬ កិ. វិ. : ពិលាបសោកស្ដាយ; យំពិលាប, ទួញពិលាប (ព. ទេ. ឬ ព. កា.) : បដាចារា ពិលាបទួញថា ប្ដីស្លាប់កូនស្លាប់ អាពុកនិងម្ដាយ ឯនាយក៏ស្លាប់ តើឲ្យខ្ញុំស្លាប់តាមដែរឬទេ ? ... (ទំនួញនាងបដាចារា) ។

[១៨] ទឹកភ្នែក

កុមារទាំងឡាយទៅ ការបូជាយញ្ញដោយបុត្ររបស់យើងល្មម លើកលែងត្រឹមនេះចុះ" ។

## ខណ្ឌហាលព្រាហ្មណ៍តឿនស្តេចឲ្យឆាប់បូជាយញ្ញ

រាជបុរសទាំងឡាយ គ្រាន់តែឮព្រះរាជឱង្ការ[១៩] នោះភ្លាម ក៏បាន នាំគ្នាដោះលែងពួកសត្វទាំងអស់ មានព្រះរាជបុត្រជាដើម រហូតដល់បក្សីជាទីបំផុត ។ ចំណែកខណ្ឌហាលព្រាហ្មណ៍ កំពុងតែចាត់ចែង

[១៩] (ន.) (សំ.) (អោំការ អ. ថ. អោម-ការ៉: "អក្សរ ឱម" ឬ "សូមសូត្ររំឭកចំពោះ ឱម !") ពាក្យប្រើជារហស្សនាម (នាមកំបាំង) របស់ពួកទេវតាស័ក្តិសិទ្ធិ គឺជាពាក្យហៅបញ្ចៀសមិនឲ្យចំឈ្មោះ ជាវាចាស័ក្តិសិទ្ធិសម្រាប់ពួកព្រាហ្មណិក សូត្រប្រសិទ្ធីឬប្រើក្នុងយញ្ញពិធីផ្សេងៗ, ច្រើនប្រើរៀងត្រង់ខាងចុងប្រយោគពាក្យសូត្រ ជាតែម្តង ៗ ក៏មាន ជាផ្ទួនពីរដង ៗ ឬបីដង ៗ ក៏មាន ។ ខ្មែរក្នុងបុរាណសម័យ, កាលដែលកំពុងប្រតិបត្តិជឿកាន់តាមលទ្ធិព្រាហ្មណ៍, ប្រើពាក្យនេះជាជំនួសព្រះបរមនាមនៃព្រះមហាក្សត្រថា ព្រះរាជឱង្ការ សំដៅសេចក្តីថា "ព្រះរាជា ឬព្រះករុណាជាអម្ចាស់ជីវិតលើត្បូង" (មិនបេញឲ្យចំព្រះបរមនាម) : ព្រះបាទសម្តេចព្រះរាជឱង្ការបរម បពិត្រក្រុងកម្ពុជាធិបតី... ។ លុះចំណោរកាលត ៗ មក ខ្មែរប្រើពាក្យនេះជាព្រះរាជតម្រាស់នៃព្រះមហាក្សត្រថា ព្រះឱង្ការ ឬ ព្រះរាជឱង្ការ, ព្រះបរមរាជឱង្ការ ប្រើជាប់រៀងដរាបមកដល់សម័យបច្ចុប្បន្ននេះ (ម. ព. រាជឱង្ការ ក្នុងពាក្យ រាជ និងពាក្យ ឱម ! ទៀតផង) ។ ឱង្ការព្រះ ព្រះបន្ទូលព្រះ គឺពុទ្ធវចនៈ ឬពុទ្ធភាសិត (ពាក្យប្រើដោយសន្មតឬឧបកិច្ចជាឈ្មោះមន្តអាគមឬពាក្យរាយសេចក្តីសម្រាប់សូត្ររម្ងាប់ឬសូត្របង្អក់ប្រសិទ្ធិជាដើម ហៅថា មន្តឱង្ការព្រះ) ។

ការងារខាងរណ្ដៅយញ្ញ ។ គ្រានោះ បុរសម្នាក់បានប្រាប់គាត់ថា “នែខណ្ឌហាលចង្រៃ ស្ដេចបានដោះលែងបុត្រអស់ហើយ អ្នកឯងចូរសម្លាប់កូន ៗ របស់ខ្លួន ហើយបូជាយញ្ញ ដោយឈាមបំពង់ករបស់ពួកគេចុះ” ។ ខណ្ឌហាលព្រាហ្មណ៍ថា “ម្ដេចក៏ស្ដេចធ្វើអ៊ីចឹង គួរបើដែរ” គាត់ក្ដៅឆេវដូចភ្លើងឆេះកប្ប ក៏បិទរណ្ដៅ រួចក្រោកឡើង ស្ទុះយ៉ាងលឿនទៅក្រាបទូលស្ដេចថា ៖

“បុត្តេហិ ខោសិ មេ វុត្តោ ទុក្ករំ ទុរភិសម្ភវញ្ចេតំ
អថ នោ ឧបក្ខដស្ស យញ្ញស្ស កស្មា ករោសិ វិក្ខេបំ ។
សព្វេ វជន្តិ សុគតិំ យេ យជន្តិ យេបិ យាជេន្តិ
យេ ចាបិ អនុមោទន្តិ យជន្តានំ ឯទិសំ មហាយញ្ញំ” ។

“ទូលព្រះបង្គំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយញ្ញនុ៎ះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងធ្វើឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញដែលទូលព្រះបង្គំប្រុងប្រៀបស្រេចហើយ ហេតុអ្វីព្រះអង្គធ្វើឲ្យខកខានទៅវិញ ? ជនទាំងឡាយណា

*បូជាយញ្ញខ្លួនឯងក្តី ឲ្យគេបូជាយញ្ញក្តី ឬគ្រាន់តែអនុមោទនា[២០] មហាយញ្ញ[២១] ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងឡាយទាំងអស់នោះ រមែងទៅកាន់សុគតិ" ។*

*ព្រះរាជាអន្ធពាល[២២]អង្គនោះ បានជឿសម្តីរបស់ព្រាហ្មណ៍អ្នកលុះក្នុងអំណាចក្តីក្រោធ សម្គាល់ថាត្រឹមត្រូវ ទ្រង់ក៏ប្រើឲ្យគេចាប់បុត្រទាំងឡាយម្តងទៀត ។ គ្រានោះ ចន្ទកុមាររំឭកព្រះបិតាថា ៖*

"អជ កិស្ស ជនោ បុត្តេ សោត្ថានំ ព្រាហ្មណោ អវាចេសិ
អជ នោ អការណស្មា យញ្ញត្ថាយ នេវ ឃាតេសិ ។
បុត្តេវ នោ ទហរកាលេ ន ហនេសិ ន ឃាតេសិ
ទហរម្ហា យោព្វនំ បត្តា អទូសកា តាត ហញ្ញាម ។
ហត្ថិគតេ អស្សគតេ សន្នទ្ធេ បស្ស នោ មហារាជ
យុទ្ធេ វា យុជ្ឈមានេ វា ន ហិ មាទិសា សូរា ហោន្តិ យញ្ញត្ថាយ ។

---

[២០] (--*មោទៈ*--) *សេចក្តីត្រេកអរតាម, ការជួយត្រេកអរ, អំណរជាមួយ; វាចាសម្តែងសេចក្តីត្រេកអរតាម* : *ធ្វើអនុមោទនា ។ ខ្មែរប្រើជាកិ.* *ផងក៏បាន "ត្រេកអរតាម, ជួយត្រេកអរ, ត្រេកអរជាមួយផង, ទទួលអំណរ" ។*

[២១] (--*យ៉ាញ់ៈញៈ ឬ--យ៉ាញ់*) ន. (បា.) *យញ្ញធំ, ការបូជាធំ (ច្រើនប្រើខាងលទ្ធិព្រាហ្មណ៍)* : *ធ្វើមហាយញ្ញ ។*

[២២] *ល្ងង់ងងឹតសូន្យឈឹង (ដូចមនុស្សខ្វាក់)* : *ជនអន្ធពាល ។*

បច្ចន្តេ វាបិ កុបិតេ　　អដវីសុ វា មាទិសេ និយោជេន្តិ
អថ នោ អការណស្មា　　អក្ខមិយំ តាត ហញ្ញាម ។
យាបិ ហិ តា សកុណិយោ វសន្តិ តិណឃរានិ កត្វាន
តាសម្បិ បិយា បុត្តា　　អថ នោ ត្វំ ទេវ ឃាតេសិ ។
មា តស្ស សទ្ទហេសិ　　ន មំ ខណ្ឌហាលោ ឃាតេយ្យ
មមញ្ហិ សោ ឃាតេត្វាន　　អនន្តរា តម្បិ ទេវ ឃាតេយ្យ ។
គាមវរំ និគមវរំ ទទន្តិ　　ភោគម្បិស្ស មហារាជ
អថគ្គបិណ្ឌិកាបិ　　កុលេ កុលេ ហេតេ ភុញ្ជន្តិ ។
តេសម្បិ តាទិសានំ　　ឥច្ឆន្តិ ទុព្ភិតុំ មហារាជ
យេភុយ្យេន ឯតេ　　អកតញ្ញុនោ ព្រាហ្មណា ទេវ ។
មា នោ ទេវ អវធិ　　ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ　　ហត្ថី អស្សេ ច ទាលេម ។
មា នោ ទេវ អវធិ　　ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ　　ហត្ថិឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ　　ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ　　អស្សឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ　　ទាសេ នោ ទេហិ ខណ្ឌហាលស្ស
យស្ស ហោន្តិ តវ កាមា　　អបិ រដ្ឋា បព្វជិតា
ភិក្ខាចរិយំ ចរិស្សាម” ។

"ចុះព្រះអង្គឲ្យពួកព្រាហ្មណ៍ ទាយអំពីសួស្តីរបស់ទូលបង្គំពីមុនមកដើម្បីអ្វី ? បពិត្រព្រះសម្មតិទេព កាលបើដូច្នេះ ព្រះអង្គឲ្យគេសម្លាប់ពួកទូលបង្គំ ដើម្បីប្រយោជន៍ដល់យញ្ញដោយឥតហេតុ ។ ចុះពីដើម កាលដែលទូលបង្គំទាំងឡាយនៅក្មេង ហេតុដូចម្តេចក៏ព្រះអង្គមិនសម្លាប់ឬមិនឲ្យគេសម្លាប់ចោលទៅ ។ បពិត្រព្រះបិតា ឥឡូវនេះ ទូលបង្គំទាំងឡាយ ធំ ៗ ពេញកំលោះ[២៣]អស់ហើយ ជាអ្នកឥតប្រទូស្តនឹងនរណាមួយឡើយ ក៏ស្រាប់តែព្រះអង្គឲ្យគេសម្លាប់ ។ បពិត្រមហារាជ សូមព្រះអង្គទតមើលទូលបង្គំទាំងឡាយ ដែលពាក់គ្រឿងក្រោះ[២៤]ជិះដំរី ជិះសេះចម្បាំង និងកំពុងចម្បាំង មនុស្សទាំងឡាយដូចទូលបង្គំនេះ មិនមែនជាមនុស្សសម្រាប់បូជាយញ្ញទេ ។ ជនទាំងឡាយ តែងបញ្ជូនពួកមនុស្សដូចទូលបង្គំ ទៅក្នុងបច្ចន្តគ្រាមដែលបះបោរឡើងហើយឬក្នុងដងព្រៃ បពិត្រព្រះបិតា កាលបើដូច្នេះ ទូលបង្គំទាំងឡាយ មិនត្រូវព្រះ

---

[២៣] (គុ.), (ន.) (កំ-ល៉ោះ) មនុស្សប្រុសដែលពេញការ, ពេញកម្លាំងល្មមមានប្រពន្ធ : មនុស្សកំលោះ, មនុស្សពេញកំលោះ ។ ភ្លើងដែលកំពុងឆេះពេញបន្ទុកក៏ហៅ ភ្លើងពេញកំលោះ ដែរ ។

[២៤] (ន.) អាវចម្បាំងធ្វើពីដែក ឬ ពាសដែក : អាវក្រោះ; ពាក់ក្រោះ ។ រថក្រោះ រថចម្បាំងសម័យបច្ចុប្បន្ន ។

អង្គឲ្យគេសម្លាប់ក្នុងទីមិនមែនជាឱកាស[២៥] ដោយឥតហេតុទេ ។ មេសត្វស្លាបទាំងឡាយណានីមួយ ធ្វើសម្បុកដោយស្មៅទាំងឡាយហើយនៅ កូនទាំងឡាយក៏បានជាទីស្រឡាញ់របស់មេសត្វស្លាបទាំងនោះ ។ បពិត្រព្រះសម្មតិទេព កាលបើដូច្នេះ ព្រះអង្គនៅតែឲ្យគេសម្លាប់ទូលបង្គំទាំងឡាយពិតមែនឬ ? សូមព្រះអង្គកុំជឿពាក្យខណ្ឌហាលព្រាហ្មណ៍នោះថា ខណ្ឌហាលព្រាហ្មណ៍ មិនគប្បីសម្លាប់យើងដូច្នេះឡើយ ។ បពិត្រព្រះសម្មតិទេព ខណ្ឌ-ហាលព្រាហ្មណ៍នោះ សម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយហើយ នឹងសម្លាប់ព្រះអង្គ ក្នុងកាលជាខាងក្រោយ ។ បពិត្រមហារាជ ព្រះរាជាទាំងឡាយ តែងព្រះរាជទានស្រុកដ៏ប្រសើរផង និគមដ៏ប្រសើរផង ភោគៈផង ដល់ព្រាហ្មណ៍នោះ កាលបើដូច្នេះ ពួកព្រាហ្មណ៍ទាំងនោះ ជាអ្នកបរិភោគរាល់ ៗ ដុំបាយដ៏ថ្លៃថ្នូង តែងបានបរិភោគរាល់ ៗ ត្រកូល ។ បពិត្រមហារាជ ព្រាហ្មណ៍ទុំះ

---

[២៥] (ន.) (បា.),(សំ.) (អវកាឝ) ហេតុ, ការណ៍; ស្ថាន, ទី, ទីទំនេរ, ចន្លោះ; វេលា, វេលាទំនេរ, ពេលស្រួល; ផ្លូវ, ទំនង; សិទ្ធិដោត; ការនិយម, ការអនុលោម; សេចក្ដីអនុញ្ញាតឲ្យ; ការយល់ព្រមតាម : ឱកាសល្អ ពេលល្អ, ទំនងស្រួល (ព. កា. ប្រើជាអវកាស ក៏បាន) ។ ព. កា. ថា : យើងទៅរកគេកុំចូលផ្ដាស ត្រូវសុំឱកាសគេជាមុន កុំស្រាប់តែចូលឲ្យហួសស៊ុន គេពុំដឹងមុនកុំអាលចូល ។ នេះគឺជាសុជីវធម៌ បវរដែលលោកតែងអនុកូល ឬអាចហៅថាច្បាប់ចេញចូល ដូច្នេះទៅវិញក៏សឹងបាន ។

ប្រាថ្នាដើម្បីប្រទូស្តចំពោះជនអ្នកឲ្យទាំងនោះ ដូចជាព្រះអង្គជាដើម ។ បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ទាំងនុ៎ះ ជាមនុស្សអកតញ្ញូដ៏ក្រៃលែង ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ទូលបង្គំទាំងឡាយ សូមជាប់ចំណងហើយនឹងឃ្វាលដំរីនិងសេះ ចាក់អាចម៍ដំរីនិងចាក់អាចម៍សេះ ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ ព្រះអង្គសព្វព្រះរាជហឫទ័យចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមព្រះរាជទាននូវទូលបង្គំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះវិញចុះ ពុំនោះសោត បើព្រះអង្គបំបរបង់ទូលបង្គំទាំងឡាយចេញចាកដែន ក៏ព្រមដែរ ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់នូវពិលាបរបស់ចន្ទកុមារហើយ ត្រាស់ដោះលែងម្តងទៀតដោយពាក្យនេះថា ៖

"ទុក្ខំ ខោ មេ ជនយថ        វិលបន្តា ជីវិតស្ស កាមា ហិ
មុញ្ចេថ ទានិ កុមារេ    អលម្បិ មេ ហោតុ បុត្តយញ្ញេន" ។

"អ្នកទាំងឡាយ ធ្វើឲ្យយើងលំបាកខ្លាំងណាស់ អ្នកទាំងឡាយយំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយ

លែងកុមារទាំងឡាយទៅ ការបូជាយញ្ញដោយបុត្ររបស់យើង
ល្មមលើកលែងចុះ" ។

ខណ្ឌហាលព្រាហ្មណ៍ មកបញ្ចោះ[២៦] ស្ដេចឲ្យចាប់ម្ដងទៀតដោយពោល
យ៉ាងនេះថា ៖

"បុត្តេហិ ទេវ យជិត្វា ទុក្ករំ ទុរភិសម្ភវំ ញាតំ
អថ នោ ឧបក្ខដស្ស យញ្ញស្ស កស្មា ករោសិ វិក្ខេបំ ។
សព្វេ វជន្តិ សុគតិំ យេ យជន្តិ យេបិ យាជេន្តិ
យេ ចាបិ អនុមោទន្តិ យជន្តានំ ឯទិសំ មហាយញ្ញំ" ។

"ទូលព្រះបង្គំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយញ្ញ
នុ៎ះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងធ្វើឲ្យកើតឡើង
បានផង កាលបើគ្រឿងយញ្ញដែលទូលព្រះបង្គំប្រុងប្រៀបស្រេច
ហើយ ហេតុអ្វីព្រះអង្គធ្វើឲ្យខកខានទៅវិញ ? ជនទាំងឡាយណា
បូជាយញ្ញខ្លួនឯងក្ដី ឲ្យគេបូជាយញ្ញក្ដី ឬគ្រាន់តែអនុមោទនា
មហាយញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្ដី ជនទាំង
ឡាយទាំងអស់នោះ រមែងទៅកាន់សុគតិ" ។

គ្រានោះ ចន្ទកុមារនិយាយប្រចុបប្រចែង[២៧] ព្រាហ្មណ៍ថា ៖

---

[២៦] (កិ.) ធ្វើឲ្យចេះ, ឲ្យយល់ដោយឲ្យគំនិត, ប្រាប់ល្បិច : បញ្ចោះគ្នាឲ្យឆ្លើយបដិសេធ ។

"យទិ កិរ យជិត្វា បុត្តេហិ ទេវលោកំ ឥតោ ចុតា យន្តិ
ព្រាហ្មណោ តាវ យជតុ បច្ឆាបិ យជសិ តុវំ រាជ ។
យទិ កិរ យជិត្វា បុត្តេហិ ទេវលោកំ ឥតោ ចុតា យន្តិ
ឯសេ្វវ ខណ្ឌហាលោ យជតំ សកេហិ បុត្តេហិ ។
ឯវំ ជានន្តោ ខណ្ឌហាលោ កិំ បុត្តកេ ន ឃាតេសិ
សព្វញ្ច ញាតិជនំ អត្តានញ្ច ន ឃាតេសិ ។
សព្វេ វជន្តិ និរយំ យេ យជន្តិ យេបិ យាជេន្តិ
យេ ចាបិ អនុមោទន្តិ យជន្តានំ ឯទិសំ មហាយញ្ញំ ។
សចេ ហិ សោ សុជ្ឈតិ យោ ហនាតិ ហតោបិ សោ
សគ្គមុបេតិ ឋានំ
ភោវាទិ ភោវាទិន មារយេយ្យុំ យេ ចាបិ តេសំ អភិសទ្ទហេយ្យុំ" ។

"បើប្រាកដជាបុគ្គលទាំងឡាយ បូជាយញ្ញដោយបុត្រទាំងឡាយ ហើយច្យុតចាកមនុស្សលោកនេះ រមែងទៅកាន់ទេវលោក បពិត្រមហារាជ ចូរព្រាហ្មណ៍បូជាមុនចុះ សឹមព្រះអង្គបូជាជាខាងក្រោយ ។ ឮថាបើប្រាកដជាបុគ្គលទាំងឡាយ បូជាយញ្ញដោយបុត្រទាំងឡាយហើយច្យុតចាកមនុស្សលោកនេះ រមែងទៅកាន់

[២៧] ប្រចុបដោយប្រឹងប្រែងពេញទី, ជួយចាត់ចែងកិច្ចការគ្រាន់តែហៃៈ ហ៍ផ្សែផ្សំ ដោយអាការប្រចុបឲ្យគេគាប់ចិត្ត ។

ទេវលោក ចូរខណ្ឌហាលព្រាហ្មណ៍ខ្លួនឯង បូជាដោយកូនទាំងឡាយរបស់ខ្លួនចុះ ។ បើខណ្ឌហាលព្រាហ្មណ៍ ដឹងយ៉ាងនេះហើយ ហេតុអ្វីក៏មិនសម្លាប់កូនតូច ៗ ទាំងឡាយផង មិនសម្លាប់ជនជាញាតិទាំងអស់ផង មិនសម្លាប់ខ្លួនឯងផងទៅ ? បើតាមសច្ចធម៌ ជនទាំងឡាយណា បូជាយញ្ញដោយខ្លួនឯងក្ដី ឲ្យគេបូជាយញ្ញក្ដី ឬគ្រាន់តែអនុមោទនាមហាយញ្ញប្រាកដដូច្នេះក្ដី ជនទាំងអស់នោះ រមែងទៅកាន់នរក" ។

បើទោះបីជាពោលបែបនេះហើយ ក៏ចន្ទកុមារនៅតែមិនអាចញ៉ាំងព្រះបិតាឲ្យជឿតាមសម្ដីខ្លួនបានជាដដែល រួចបានពោលប្រារព្ធទៅបរិស័ទដែលឈរជុំវិញស្ដេចនោះជាបន្តថា ៖

"កថញ្ចិ ក៏រ បុត្តកាមាយោ គហបតយោ ឃរណិយោ ច
នគរម្ហិ ន ឧបរវន្តិ រាជានំ មា ឃាតយិ ឱរសំ បុត្តំ ។
កថញ្ចិ ក៏រ បុត្តកាមាយោ គហបតយោ ឃរណិយោ ច
នគរម្ហិ ន ឧបរវន្តិ រាជានំ មា ឃាតយិ អត្រជំ បុត្តំ ។
រញ្ញោ ចម្ហិ អត្ថកាមោ ហិតោ ច សព្ពជនបទស្ស
ន កោចិ អស្ស បដិឃំ មយា ជានបទោ ន បវេទេតិ" ។

"ម្ដេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា សូមទ្រង់កុំសម្លាប់

បុត្រដែលកើតអំពីទ្រង់ឡើយ ។ ម្ដេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា សូមទ្រង់កុំសម្លាប់បុត្រដែលកើតអំពីខ្លួនឡើយ ។ ខ្ញុំជាអ្នកប្រាថ្នាប្រយោជន៍ចំពោះព្រះរាជា ប្រយោជន៍ចំពោះអ្នកជនបទទាំងអស់ ឥតមាននរណាមួយថ្នាំងថ្នាក់ចិត្តនឹងខ្ញុំឡើយ ហេតុអ្វី ក៏អ្នកជនបទមិនក្រាបទូលឲ្យទ្រង់ជ្រាប ?”

កាលបើចន្ទកុមារពោលយ៉ាងនេះ គ្មាននរណាមួយហ៊ានហើបមាត់ស្ដីថាអ្វីមួយម៉ាត់ឡើយ ។ គ្រានោះ ចន្ទកុមារប្រើភរិយាទាំងឡាយរបស់ខ្លួនឲ្យអង្វរព្រះរាជាថា ៖

“គច្ឆថ ភោ ឃរណិយោ    តាតញ្ច វទេថ ខណ្ឌហាលញ្ច
មា ឃាតេថ កុមារេ    អទូសកេ សីហសង្កាសេ ។
គច្ឆថ ភោ ឃរណិយោ    តាតញ្ច វទេថ ខណ្ឌហាលញ្ច
មា ឃាតេថ កុមារេ    អបេក្ខិតេ សព្វលោកស្ស” ។

“ម្នាលនាងឃរណី (ស្រីមេផ្ទះ) ទាំងឡាយ ចូរនាងទាំងឡាយទៅអង្វរព្រះរាជបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារទាំងឡាយ ដូចជាសីហៈ ជាអ្នកមិនប្រទូស្ត ម្នាលនាងឃរណីទាំងឡាយ ចូរពួកនាងទៅនិយាយអង្វរព្រះបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារទាំង

ឡាយ ជាទីអាល័យរបស់សត្វលោកទាំងអស់ឡើយ" ។

ទោះបីស្ត្រីទាំងឡាយនោះ ក្រាបទូលសូមអង្វរយ៉ាងណាក៏ដោយ ក៏ព្រះរាជាមិនយកព្រះទ័យទុកដាក់អើពើ មិនក្រឡេកមើលដែរ ។ គ្រានោះ កុមារឥតទីពឹងទួញពិលាបថា ៖

"យំនូនាហំ ជាយេយ្យំ រថការកុលេសុ វា
បុក្កុសកុលេសុ វា វេស្សេសុ វា ជាយេយ្យំ
ន ហជ្ជ មំ រាជ យញ្ញេ ឃាតេយ្យ" ។

"បើអញកើតក្នុងត្រកូលអ្នកធ្វើរថ ឬអ្នកចោលសំរាម ឬកើតក្នុងត្រកូលវេស្សៈ ម្ល៉េះសមព្រះរាជានឹងមិនសម្លាប់អញដើម្បីយញ្ញឡើយ ក្នុងថ្ងៃនេះ" ។

និយាយដូច្នេះហើយ ចន្ទកុមារប្រើករិយាទាំងឡាយនោះឲ្យទៅម្តងទៀតថា ៖

"សព្វា សីមន្តិនិយោ គច្ឆថ អយ្យស្ស ខណ្ឌហាលស្ស
បាទេសុ និបតថ អបរាធាហំ ន បស្សាមិ ។
សព្វា សីមន្តិនិយោ គច្ឆថ អយ្យស្ស ខណ្ឌហាលស្ស
បាទេសុ និបតថ កិន្តេ ភន្តេ មយំ អទូសេម" ។

"ម្នាលពួកស្រី ៗ អ្នកមានគំនិតទាំងឡាយ ចូរនាងទាំងអស់ទៅក្រាបជិតជើងនៃខណ្ឌហាលព្រាហ្មណ៍ហើយប្រាប់ថា ខ្ញុំមិនឃើញកំហុសសោះ ។ ម្នាលពួកស្រីជាមេផ្ទះទាំងអស់គ្នា ចូរនាងទាំងឡាយទៅក្រាបជិតជើងនៃខណ្ឌហាលព្រាហ្មណ៍ហើយនិយាយថា បពិត្រលោកខណ្ឌហាលព្រាហ្មណ៍ដ៏ចម្រើន យើងទាំងឡាយបានប្រទូស្តអ្វីដល់លោក" ។

លំដាប់នោះ កនិដ្ឋកគិនី[២៨]របស់ចន្ទកុមារ ឈ្មោះសេលកុមារី បានឃើញព្រះភាតា[២៩] ទាំងឡាយដែលគេនាំខ្លួនទៅ ដ៏គួរឲ្យអាណិត មិនអាចទប់សេចក្តីសោកបាន ក៏ក្រាបទៀបបាទមូល[៣០]របស់ព្រះបិតា ទ្រង់ព្រះកន្សែងខ្សឹកខ្សួលថា ឮថាព្រះរាជបិតាអញ ព្រោះតែប្រាថ្នាឋានសួគ៌ ទ្រង់បានយកបុត្រនិងមហេសីទាំងឡាយទៅបូជាយញ្ញ ។

## វសុលកុមារបុត្រនៃចន្ទកុមារពិលាប

សូម្បីសម្តីរបស់សេលកុមារី ក៏ព្រះរាជាទ្រង់ពុំជឿស្តាប់ដែរ ។ គ្រានោះ បុត្រនៃចន្ទកុមារ ព្រះនាមថា វសុល ឃើញព្រះបិតាមានទុក្ខ គិត

---

[២៨] ប្អូនស្រី

[២៩] (ន.) (បា.),(សំ.) (ភាតុ > ភាតា; ភ្រាតួ) បងប្អូនប្រុស; (រ. ស.) : ព្រះភាតា ។ កនិដ្ឋភាតា ប្អូនប្រុស; ជេដ្ឋភាតា បងប្រុស (រ. ស.) ។

[៣០] (ន.) (សំ.),(បា.) (បាទ:--) ទីតាំងនៃជើង, ទីជិតជើង : ក្រាបទៀបបាទមូល ។

ថា "អញនឹងអង្វរព្រះអយ្យកោ[៣១] សូមឲ្យទ្រង់ប្រទានជីវិតដល់បិតាអញ" ក៏ទ្រង់បម្រះននៀលក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ទ្រង់ព្រះកន្សែងខ្សឹកខ្សួល អង្វរទៀបបាទមូលរបស់ព្រះរាជាថា ៖

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំសម្លាប់បិតារបស់ទូលបង្គំឡើយ ព្រោះទូលបង្គំនៅក្មេង ពុំទាន់ធំដឹងក្ដីនៅឡើយទេ" ។

ព្រះរាជា ឮសេចក្ដីខ្សឹកខ្សួលរបស់ចៅ ទ្រង់ស្ទើរបែកហឫទ័យ ទ្រង់ក៏បានឱបព្រះកុមារទាំងទឹកនេត្រាហូរស្រក់ចុះមក ហើយត្រាស់ថា ៖

"នែចៅ ចៅឯងចូរដកដង្ហើមឲ្យស្រួលចុះ យើងមុខតែលែងបិតាឯងទេ" ។

រួចទ្រង់ត្រាស់ទៀតថា ៖

"ឯសោ តេ វសុល បិតា សមេហិ បិតរា សហ
ទុក្ខំ ខោ មេ ជនយសិ វិលបន្តោ អន្តេបុរស្មិំ
មុញ្ចេជ ធានិ កុមារេ អលម្បិ មេ ហោតុ បុត្តយញ្ញេន" ។

"ម្នាលវសុលកុមារ នុ៎ះបិតារបស់ឯង ចូរឯងស្ងប់រំងាប់ជាមួយ

---

[៣១] (ន.) (បា.),(សំ.) (អ័យ-យ៉ះក:) (អាយ៌ក) ជីតា, តា ។ ខ្មែរប្រើ រ. ស. ជា *អយ្យកោ*, ប្រើជា ព្រះអយ្យកោ, សម្ដេចព្រះរាជអយ្យកោ, ព្រះអយ្យកោទួត, --លួត, --លា ។

នឹងបិតាឯងចុះ ឯងយំស្រែកក្នុងព្រះរាជវាំង ឈ្មោះថា ញុំាង
ទុក្ខយ៉ាងខ្លាំងឲ្យកើតឡើងដល់អយ្យកោ អ្នកទាំងឡាយចូរលែង
ពួកកុមារក្នុងកាលឥឡូវនេះចុះ ការបូជាយញ្ញដោយបុត្ររបស់
យើង លើកលែងចុះ" ។

ខណ្ឌហាលព្រាហ្មណ៍ មកម្តងទៀតពោលថា ៖

"បុត្តេវ ទោសិ មេ វុត្តោ        ទុក្ករំ ទុរភិសម្ភវំ ញ្ចេតំ
អថ នោ ឧបក្ខដស្ស យញ្ញស្ស     កស្មា កកោសិ វិក្ខេបំ ។
សព្វេ វជន្តិ សុគតិំ             យេ យជន្តិ យេបិ យាជេន្តិ
យេ ចាបិ អនុមោទន្តិ          យជន្តានំ ឯទិសំ មហាយញ្ញំ" ។

"ទូលព្រះបង្គំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយញ្ញ
នុ៎ះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងធ្វើឲ្យកើតឡើង
បានផង កាលបើគ្រឿងយញ្ញដែលទូលព្រះបង្គំប្រុងប្រៀបស្រេច
ហើយ ហេតុអ្វីព្រះអង្គធ្វើឲ្យខកខានទៅវិញ ? ជនទាំងឡាយណា
បូជាយញ្ញខ្លួនឯងក្តី ឲ្យគេបូជាយញ្ញក្តី ឬគ្រាន់តែអនុមោទនា
មហាយញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំង
ឡាយទាំងអស់នោះ រមែងទៅកាន់សុគតិ" ។

ចំណែកព្រះរាជា ហេតុតែទ្រង់ជាមនុស្សអន្ធពាល បានបញ្ជាឲ្យគេ

ចាប់បុត្រទាំងឡាយម្ដងទៀត តាមពាក្យរបស់ព្រាហ្មណ៍នោះ ។ គ្រានោះ ខណ្ឌហាលគិតថា "ព្រះរាជានេះមានហឫទ័យទន់ជ្រាយណាស់ ម្ដងឲ្យគេចាប់ ម្ដងឲ្យគេលែង មុខតែទ្រង់ឲ្យគេលែងបុត្រដោយពាក្យរបស់ទារក[៣២] ទាំងឡាយម្ដងទៀតពុំខាន អញនឹងនាំទ្រង់ទៅកាន់រណ្ដៅយញ្ញតែម្ដង" ។ ព្រាហ្មណ៍ក៏យាងព្រះរាជា ដោយនិយាយថា ៖

"បពិត្រព្រះករុណាថ្លៃវិសេស យញ្ញទូលបង្គំ បានចាត់ចែងរៀបចំ ដើម្បីព្រះអង្គដោយរតនៈទាំងពួងហើយ បពិត្រព្រះសម្មតិទេព សូមព្រះអង្គយាងចេញទៅ ព្រះអង្គនឹងទៅរីករាយក្នុងឋានសួគ៌" ។

## ពួកស្រីស្នំពិលាប

គ្រានោះ ពេលដែលយកព្រះពោធិសត្វទៅកាន់រណ្ដៅយញ្ញ ស្នំទាំងឡាយចំនួន ៧០០ នាក់នៅក្មេង ៗ ដែលជាភរិយារបស់ចន្ទកុមារ រំសាយកេសា ទួញយំដើរតាមផ្លូវទៅជាមួយ ។ ចំណែកពួកស្ត្រីឯទៀត ក៏ចេញទៅដោយសេចក្ដីសោកស្ដាយ រំសាយកេសា ទួញយំ ដើរតាមផ្លូវទៅដែរ មើលទៅដូចទេវតាចោមរោមទេវបុត្រ ដែលរៀបច្យុតក្នុងនន្ទវ័នឧទ្យាន[៣៣]ដូច្នោះ ។ ស្ត្រីទាំងឡាយនោះ ទួញពិលាប ដូច្នេះ ៖

---

[៣២] (ន.) (សំ.),(បា.) (--រក់) ក្មេងប្រុស, ក្មេងប្រុសតូច ។ បើក្មេងស្រី ទារិកា ។

[៣៣] (ន.) (សំ.) (អ៊ុត-ទ្យាន) (< ឧត៑ > ឧទ៑ + យាន; បា. ឧយ្យាន "ទីសម្រាប់កម្សាន្តមានដើមឈើខ្ពស់ ៗ ដែលគេចូលដល់ គេដើរបណ្ដើរងើយមើលលើបណ្ដើរ") សួនដែល

"កាសិកសុចិវត្ថធរា　　កុណ្ឌលិនោ អគលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសូរិយា　　យញ្ញត្ថាយ ឯករាជស្ស ។
កាសិកសុចិវត្ថធរា　　កុណ្ឌលិនោ អគលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសូរិយា　　មាតុ កត្វា ហទយសោកំ ។
កាសិកសុចិវត្ថធរា　　កុណ្ឌលិនោ អគលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសូរិយា　　ជនស្ស កត្វា ហទយសោកំ ។
មំសរសភោជនា ន្ហាបកសុន្ហាបិតា　　កុណ្ឌលិនោ
អគលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសូរិយា　　យញ្ញត្ថាយ ឯករាជស្ស ។
មំសរសភោជនា ន្ហាបកសុន្ហាបិតា　　កុណ្ឌលិនោ
អគលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសូរិយា　　មាតុ កត្វា ហទយសោកំ ។
មំសរសភោជនា ន្ហាបកសុន្ហាបិតា　　កុណ្ឌលិនោ
អគលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសូរិយា　　ជនស្ស កត្វា ហទយសោកំ ។
យស្សុ បុព្វេ ហត្ថិវរធុរគតេ　ហត្ថីហិ អនុវជន្តិ
ត្យជ្ជ ចន្ទសូរិយា　　ឧភោវ បត្តិកា យន្តិ ។

---

*មានឈើខ្ពស់ ៗ មានផ្កាផ្លែនិងលម្អគួរឲ្យចង់ដើរមើលកម្សាន្តចិត្ត, សួនមានឈើជាម្លប់សម្រាប់ដើរលេងកែអផ្សុក (ខ្មែរច្រើនប្រើក្លាយជា ឧទ្យាន) ។*

យស្សុ បុត្តេ អស្សវេធុរគតេ អស្សេហិ អនុវជន្តិ
ត្យជ្ជ ចន្ទសូរិយា ឧភោវ បត្តិកា យន្តិ ។
យស្សុ បុត្តេ រថវេធុរគតេ រថេហិ អនុវជន្តិ
ត្យជ្ជ ចន្ទសូរិយា ឧភោវ បត្តិកា យន្តិ ។
យេហិស្សុ បុត្តេ និយ្យំសុ តបនីយកប្បនេហិ តុរង្គេហិ
ត្យជ្ជ ចន្ទសូរិយា ឧភោវ បត្តិកា យន្តិ” ។

“ចន្ទកុមារនិងសុរិយកុមារ ស្មៀកដណ្តប់សំពត់ដ៏ស្អាតដែលកើត ក្នុងដែនកាសី ជាអ្នកទ្រទ្រង់កុណ្ឌល[38] លាបស្រឡាបដោយ កំញាន[39] និងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅ ដើម្បីប្រយោជន៍ដល់ យញ្ញនៃព្រះបាទឯករាជ ។ ចន្ទកុមារនិងសុរិយកុមារ ជាអ្នក ស្មៀកពាក់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុង ហឫទ័យនៃមាតា ត្រូវគេនាំយកទៅ ។ ចន្ទកុមារនិងសុរិយកុមារ ជាអ្នកស្មៀកពាក់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់ កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ធ្វើសេចក្តី

[38] (ន.) (សំ.),(បា.) (កុន-ឌល់) ប្រដាប់សម្រាប់ពាក់ត្រចៀក មានទំហូ, ការ ជាដើម ។

[39] (ន.)--ញ៉ាន ឈ្មោះឈើមួយប្រភេទ មានជ័រក្រអូប; ជ័រនោះក៏ហៅថា កំញាន ដែរ ។ ឈ្មោះស្វាមួយប្រភេទ ហៅថា ស្វាកំញាន ។

សោកក្នុងហប្ញទ័យនៃជន ត្រូវគេនាំយកទៅ ។ ចន្ទកុមារនិង សុរិយកុមារ ដែលជាអ្នកសោយសាច់ដ៏មានរសឆ្ងាញ់ ជាអ្នកដែលខ្ពាន់ព្រះកេសផ្ងូតទឹកស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅដើម្បីប្រយោជន៍ដល់យញ្ញនៃព្រះបាទឯករាជ ។ ចន្ទកុមារនិងសុរិយកុមារ ជាអ្នកសោយនូវសាច់ដ៏មានរសឆ្ងាញ់ ជាអ្នកដែលខ្ពាន់ព្រះកេសផ្ងូតទឹកស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហប្ញទ័យនៃមាតា ត្រូវគេនាំយកទៅ ។ ចន្ទកុមារនិងសុរិយកុមារ ជាអ្នកសោយសាច់ដ៏មានរសឆ្ងាញ់ ជាអ្នកដែលខ្ពាន់ព្រះកេសផ្ងូតទឹកហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហប្ញ-ទ័យនៃជន ត្រូវគេនាំយកទៅ ។ កាលពីមុន ពួកពលដំរី តែងតែហែហមចន្ទកុមារនិងសុរិយកុមារណា ដែលគង់លើខ្នងដំរីដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារនិងសុរិយកុមារទាំងពីរព្រះអង្គនោះយាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ពួកពលសេះ តែងតាមហែចន្ទកុមារនិងសុរិយកុមារណា ដែលគង់លើខ្នងសេះដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារនិងសុរិយកុមារទាំងពីរព្រះអង្គនោះយាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ពួកពលរថ តែងតាមហែចន្ទកុមារនិងសុរិយកុមារណា ដែលគង់ក្នុងកណ្តាលរថដ៏

ប្រសើរ ថ្ងៃនេះ ចន្ទកុមារនិងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ចន្ទកុមារនិងសុរិយ-កុមារណា ស្ដេចទៅដោយព្រះទីនាំងអស្សតរ[៣៦] ដែលតាក់តែង ដោយគ្រឿងមាស ថ្ងៃនេះ ចន្ទកុមារនិងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ" ។

## មហាជនពិលាប

កាលបើស្រីស្នំទាំងឡាយនោះ កំពុងតែខ្សឹកខ្សួលយ៉ាងនេះ ពួករាជបុរសបាននាំព្រះពោធិសត្វចេញអំពីនគរ ។ អ្នកនគរទាំងមូល ក៏នាំគ្នាផ្អើលឈូឆរចេញទៅតាមយ៉ាងកកកុញ ធ្វើឲ្យប្រកទ្វារនគរទាំងឡាយ កកស្ទះ ណែនណាន់តាន់តាប់ គ្មានសល់ចន្លោះដល់តិចតួចឡើយ ។ ខណ្ឌហាលព្រាហ្មណ៍ កាលបើឃើញមនុស្សច្រើនពេក បានបញ្ជាឲ្យគេបិទទ្វារនគរទាំងអស់ ដោយនឹកថា "តើនរណានឹងដឹងថាមានអ្វីកើតឡើង" ។ ឯមហាជន កាលចេញទៅមិនរួច ក៏នាំគ្នាស្រែកទ្រហោយំខ្លាំង ៗ នៅខាងក្នុងទ្វារ ក្បែរឧទ្យាននោះឯង ។ សូម្បីហ្វូងបក្សី ក៏ផ្អើលស្ទុះហើរទៅកាន់អាកាស ដោយសារសម្រែកនោះដែរ ។ មហាជន នាំគ្នាទួញយំស្រែកប្រាប់សត្វស្លាបទាំងនោះថា ៖

"ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់[៣៧]ស្មារតី ទ្រង់យក

---

[៣៦] សេះដ៏ប្រសើរជាងសេះទាំងឡាយ ។

ព្រះរាជបុត្រ ៤ ព្រះរាជកញ្ញា ៤ ព្រះមហេសី ៤ គហបតី ៤ ដំរី ៤ សេះ ៤ គោឧសភៈ ៤ និងសត្វមួយមុខ ៤ ៗ បូជាយញ្ញក្នុងទីនុ៎ះ" ។

មហាជនខ្សឹកខ្សួលក្នុងទីនោះយ៉ាងនេះ ហើយបានទៅលំនៅឋានរបស់ព្រះពោធិសត្វ ក៏ធ្វើប្រទក្សិណប្រាសាទ កាលឃើញនូវកូដាគារឧទ្យានជាដើម ខាងក្នុងបុរី គេបានខ្សឹកខ្សួលយ៉ាងនេះថា ៖

"ប្រាសាទ ផ្ទះកំពូលនេះ ជាវិការៈនៃមាស ដេរដាសដោយផ្កាកម្រង ៗ ឧទ្យាន ព្រៃអសោក ព្រៃកណិការ[៣៨] ព្រៃប្រទៀង ព្រៃស្វាយនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ។ ស្រះបោក្ខរណីនេះ ដេរដាសពាសពេញដោយផ្កាឈូកស ឈូកក្រហម ទាំងទូកដែលរចនាដោយមាស វិចិត្រដោយក្បឹវល្លិ ជាទីរីករាយចិត្តដ៏ក្រៃលែង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំ

---

[៣៧] (កិ.) (បា.) (ភន្ត "ភ្ញាក់, ភ្ញាក់ផ្អើល; ច្រឡំ, ស្រឡាំងកាំង, មិងមាំង") ជ្រួស, ច្រឡំ, ទាស់ខុសផ្លូវខុសទំនង (ក័ន្ត មិនសូវប្រើ ច្រើនប្រើតែ ភាន់ មកយូរហើយ) : ភាន់គំនិត, ភាន់ស្មារតី, ភាន់ដំណើរ, ភាន់ផ្លូវ ។

[៣៨] ឈ្មោះឈើផ្កាមួយប្រភេទមានផ្កាពណ៌សផង លឿងផង និងពណ៌មាសផង មានក្លិនក្រអូប ។ ផ្កានេះមានតំណាលច្រើនក្នុងព្រះពុទ្ធសាសនា ។ ផ្កាកណិការ កាលចាប់ក្រពុំរីករហូតដល់ផ្កាចាស់ រមែងរក្សានូវភាពស្រស់ជានិច្ច គឺមិនពោយឬចាស់តាមសភាពនៃអាយុឡើយ ជាពិសេសការរក្សាបាននូវពណ៌មាស យ៉ាងឆ្អិនឆ្អៅ គួរជាទីរីករាយ ។

ចេញទៅសម្លាប់" ។

កាលពិលាបក្នុងហេតុប៉ុណ្ណោះហើយ ពួកគេនាំគ្នាចូលទៅរោងដំរីជាដើម ហើយពិលាបទៀតថា ៖

"ឥទមស្ស ហត្ថិរតនំ    ឯរាវណោ គជោ ពលី ទន្តី
តេសានិ អយ្យបុត្តា    ចត្តារោ វធាយ និន្នីតា ។
ឥទមស្ស អស្សរតនំ    ឯកខុរោ អស្សោ
តេសានិ អយ្យបុត្តា    ចត្តារោ វធាយ និន្នីតា ។
អយមស្ស អស្សរថោ  សាឡិយនិគ្ឃោសោ សុភោ រតនវិចិត្តោ
យត្ថស្សុ អយ្យបុត្តា    សោភិំសុ នន្ទនេ វិយ ទេវា
តេសានិ អយ្យបុត្តា    ចត្តារោ វធាយ និន្នីតា ។
កថំ នាម សាមសមសុន្ទរេហិ    ចន្ទនមុទុកគត្តេហិ
រាជា យជិស្សតេ យញ្ញំ    សម្មូឡ្ហោ ចតូហិ បុត្តេហិ ។
កថំ នាម សាមសមសុន្ទរាហិ    ចន្ទនមុទុកគត្តាហិ
រាជា យជិស្សតេ យញ្ញំ    សម្មូឡ្ហោ ចតូហិ កញ្ញាហិ ។
កថំ នាម សាមសមសុន្ទរាហិ    ចន្ទនមុទុកគត្តាហិ
រាជា យជិស្សតេ យញ្ញំ    សម្មូឡ្ហោ ចតូហិ មហេសីហិ ។
កថំ នាម សាមសមសុន្ទរេហិ    ចន្ទនមុទុកគត្តេហិ
រាជា យជិស្សតេ យញ្ញំ    សម្មូឡ្ហោ ចតូហិ គហបតីហិ ។

យថា ហោន្តិ គាមនិគមា សុញ្ញា អមនុស្សកា ព្រហារញ្ញា
តថា ហេស្សតិ បុប្ផវតិយា យិដ្ឋេសុ ចន្ទសូរិយេសុ" ។

"ដំរីរ័តន៍នេះ ជាដំរីឈ្មោះឯរាវ័ណ[៣៩] មានកម្លាំង មានក្មុក ។ សេះរ័តន៍នេះ ជាសេះមានក្រចកមួយ មានសន្ទុះរហ័ស ។ រថសេះនេះ មានសូរសព្ទដូចសំឡេងនៃស្រូវសាលី ជារថដ៏ស្អាត វិចិត្រដោយរតនវត្ថុ ជាលម្អរបស់ពួកព្រះអយ្យបុត្រ ដូចជាពួកទេវតាក្នុងនន្ទ-វ័ន ។ ម្ដេចក៏ព្រះរាជាភាន់ច្រឡំ ចំពោះការបូជាយញ្ញដោយព្រះរាជបុត្រទាំង ៤ អង្គ ព្រះរាជកញ្ញាទាំង ៤ អង្គ ព្រះមហេសីទាំង ៤ អង្គ និងគហបតីទាំង ៤ នាក់ ដែលពួកគេមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាតស្អំ ឥតមានទោស មានខ្លួនលាបដោយខ្លឹមចន្ទន៍យ៉ាងនេះ ។ ស្រុកនិងនិគមទាំងឡាយ សូន្យគ្មានមនុស្ស ក្លាយទៅជាព្រៃធំ យ៉ាងណាមិញ កាលបើចន្ទកុមារនិងសុរិយកុមារ ត្រូវព្រះរាជាយកទៅបូជាយញ្ញហើយ ក្រុងបុប្ផវតីក៏នឹងស្ងាត់សូន្យឈឹងយ៉ាងនោះដែរ" ។

[៣៩] (ន.) (បា.) (អេរ៉ាវ៉ាន់) (ឯរាវណ; សំ. ឰរាវណ) ឈ្មោះដំរីមានក្បាលបីជាព្រះទីន័ងព្រះឥន្ទ្រ : ដំរីឯរាវ័ណ (គម្ពីរពុទ្ធសាសនាប្រាប់សេចក្ដីថា ក្នុងឋានសួគ៌គ្មានសត្វតិរច្ឆានមែនទែនទេ, ដែលហៅថា ដំរីឯរាវ័ណ នេះជាឈ្មោះនៃទេវបុត្តម្នាក់ដែលតែងតែនិម្មិតខ្លួនជាដំរីមានក្បាលបីមួយដងមួយកាល...) ។ ឰរាវ័ណ (អៃរ៉ាវ៉ាន់)

## ព្រះមាតាគោតមិទេវីពិលាប

គ្រានោះ មហាជនដែលចេញទៅខាងក្រៅមិនបាន ក៏បានដើរយំខ្សឹកខ្សួល នៅតែខាងក្នុងនគរប៉ុណ្ណោះ ។ ចំណែកព្រះពោធិសត្វ ត្រូវគេនាំទៅកាន់រណ្ដៅយញ្ញ ។ គ្រានោះ ព្រះមាតារបស់ព្រះពោធិសត្វព្រះនាម **គោតមិទេវី** ទ្រង់ព្រះកន្សែងសោយសោក បម្រះនឿលទៀបបាទមូលរបស់ព្រះរាជាថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គប្រទានជីវិតដល់បុត្រទាំងឡាយនៃខ្ញុំម្ចាស់ផង ក្រាបទូល" ហើយព្រះនាងបានពិលាបថា ៖

> "ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាកសេចក្ដីចម្រើន ប្រឡាក់ប្រឡូសដោយអាចម៍ដីពុំខាន បើព្រះអង្គឲ្យគេសម្លាប់ចន្ទកុមារនិងសុរិយ-កុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងក្សិណក្ស័យជាក់ជាពុំខានឡើយ" ។

ទោះបីព្រះនាងខ្សឹកខ្សួលយ៉ាងណាក៏ដោយ ក៏ព្រះនាងពុំបានសម្ដីអ្វីមួយម៉ាត់អំពីព្រះរាជាដែរ ។ ព្រះនាងមានសវនីយ៍ថា "បុត្ររបស់ខ្ញុំម្ចាស់ នឹងក្រោធចំពោះព្រះអង្គ នៅពេលបានទៅហើយ ម្ដេចឡើយក៏ព្រះអង្គឲ្យគេត្រឡប់វិញ" ហើយព្រះនាងក៏ឱបករិយាទាំង ៤ របស់ចន្ទកុមារ រួចខ្សឹកខ្សួលថា ៖

"ស្ត្រីទាំងឡាយនេះ គឺនាងយដ្ឋិកា នាងឧបរិក្ខី នាងបោក្ខរណី និងនាងគាយិកា ជាអ្នកពោលពាក្យគួរជាទីស្រឡាញ់ ទៅរកគ្នានឹងគ្នា ម្តេចក៏មិនរាំឲ្យចន្ទកុមារនិងសុរិយកុមារ សប្បាយរីករាយ ព្រោះស្ត្រីដទៃណាមួយស្មើដោយស្ត្រីទាំងនោះ មិនមានទេ" ។

លុះខ្សឹកខ្សួលជាមួយនឹងសុណិសាដូច្នេះហើយ កាលភ្ញឹកនឹកអ្វីមិនឃើញ ក៏បានជេរខណ្ឌហាលព្រាហ្មណថា ៖

"យើងមានហឫទ័យសោកស្តាយចន្ទកុមារនិងសុរិយកុមារ ដែលត្រូវគេនាំទៅសម្លាប់ណាស់ ។ នែខណ្ឌហាលព្រាហ្មណ៍ ចូរម្តាយនិងប្រពន្ធអ្នកឯង ទទួលយកសេចក្តីសោកក្នុងហឫទ័យនៃយើងនេះចុះ ។ អ្នកឯងសម្លាប់ពួកកុមារ ដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត ដែលសត្វលោកទាំងអស់អាឡោះអាល័យ នៃខណ្ឌហាលព្រាហ្មណ៍ សូមឲ្យម្តាយនិងប្រពន្ធអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្តីផងសោះឡើយ" ។

## ចន្ទកុមារពិលាប

ចន្ទកុមារពោធិសត្វ សូម្បីបិតនៅក្នុងរណ្តៅ ក៏អង្វរព្រះបិតាថា ៖

"មា នោ ទេវ អវធិ　　ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ　ហត្ថី អស្សេ ច បាលេម ។

មា នោ ទេវ អវធិ ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ ហត្ថិឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ អស្សឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ ទាសេ នោ ទេហិ ខណ្ឌហាលស្ស
យស្ស ហោន្តិ តវ កាមា អបិ រដ្ឋា បព្ពាជិតា ភិក្ខាចរិយំ
ចរិស្សាម ។
ទិព្វំ ទេវ ឧបយាចន្តិ បុត្តត្ថិកាបិ ទលិទ្ទា
បដិភានានិបិ ហិត្វា បុត្តេ ន លភន្តិ ឯកច្ចា ។
អាសីសិកានិ ករោន្តិ បុត្តា នោ ជាយន្តុ តតោ បបុត្តា
អថ នោ អការណស្មា យញ្ញត្ថាយ ទេវ ឃាតេសិ ។
ឧបយាចិតកេន បុត្តំ លភន្តិ មា តាត នោ អឃាតេសិ
មា កិច្ឆាលទ្ធកេហិ បុត្តេហិ យជិត្ថោ ឥមំ យញ្ញំ ។
ឧបយាចិតកេន បុត្តំ លភន្តិ មា តាត នោ អឃាតេសិ
មា កបណលទ្ធកេហិ បុត្តេហិ អម្មាយ នោ វិប្បវាសេហិ” ។

*“បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ។ សូមឲ្យខ្ញុំព្រះអង្គទាំងឡាយជាអ្នកជាប់ចំណង ហើយឃ្វាលដំរីនិងសេះ ចោលអាចម៍ដំរី អាចម៍*

សេះ ។ ពុំនោះសោត ទូលបង្គំទាំងឡាយ បើព្រះអង្គបំបរបង់ចេញចាកដែន ក៏ព្រមដែរ ។ បពិត្រព្រះសម្មតិទេព នារីពួកខ្លះសូម្បីជាស្ត្រីកម្សត់ នៅតែចង់បានកូន ហើយបន់ស្រន់ទេព្តា ស៊ូទ្រាំចាញ់គភ៌ នៅតែមិនបានកូនទាំងឡាយក៏មាន ។ នារីពួកខ្លះធ្វើពាក្យប្រកបដោយសេចក្តីប៉ុនប៉ងថា កូនទាំងឡាយរបស់យើងចូរកើតបន្ទាប់ពីនោះ ចៅទាំងឡាយចូរកើតទៀត ។ បពិត្រព្រះសម្មតិទេព កាលបើដូច្នេះ ហេតុអ្វីក៏ព្រះអង្គសម្លាប់ទូលបង្គំទាំងឡាយ ដើម្បីបូជាយញ្ញដោយមិនសមហេតុផលសោះយ៉ាងនេះ ។ ពួកស្ត្រីតែងបានកូន ដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ ព្រះអង្គកុំបូជាយញ្ញនេះដោយបុត្រទាំងឡាយ ដែលបានដោយលំបាកឡើយ ។ ពួកស្ត្រីតែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ សូមព្រះអង្គកុំញ៉ាំងទូលបង្គំទាំងឡាយ ឲ្យព្រាត់ប្រាសចាកមាតានិងបុត្រទាំងឡាយ ដែលបានដោយលំបាកឡើយ" ។

បើទុកណាជាពោលយ៉ាងនេះហើយ ចន្ទកុមារនោះពុំបានអ្វីអំពីសម្នាក់របស់ព្រះបិតាសោះ ក៏ក្រាបចុះទៀបបាទមូលនៃព្រះមាតា ពោលខ្សឹកខ្សួលដូច្នេះថា ៖

"ពហុទុក្ខា ធោសិយ ចន្ទំ   អម្ម តុវំ ជីយសេ បុត្តំ
វន្ទាមិ ខោ តេ បាទេ   លភតំ តាតោ បរលោកំ ។
ហន្ទ ច មំ ឧបគូហ   បាទេ តេ អម្ម វន្ទិតុំ ទេហិ
គច្ឆាមិ ទានិ បវាសំ   យញ្ញត្ថាយ ឯកកាជស្ស ។
ហន្ទ ច មំ ឧបគូហ   បាទេ តេ អម្ម វន្ទិតុំ ទេហិ
គច្ឆាមិ ទានិ បវាសំ   មាតុ កត្វា ហទយសោកំ ។
ហន្ទ ច មំ ឧបគូហ   បាទេ តេ អម្ម វន្ទិតុំ ទេហិ
គច្ឆាមិ ទានិ បវាសំ   ជនស្ស កត្វា ហទយសោកំ" ។

*"បពិត្រព្រះមាតា ព្រះអង្គបានបង្កើតបុត្រ គឺទូលបង្គំមក មានទុក្ខព្រួយច្រើនណាស់ ព្រោះតែការចិញ្ចឹម ទូលបង្គំជាបុត្រសូមក្រាបថ្វាយបង្គំព្រះបាទានៃព្រះមាតា សូមឲ្យព្រះរាជបិតាបានទៅបរលោកដែលបរិបូរដោយសម្បត្តិចុះ ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបក្រៀកទូលបង្គំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ទូលបង្គំមានតែញុំាងសេចក្ដីសោកក្នុងហឫទ័យនៃព្រះមាតាផង នៃជនទាំងឡាយផងឲ្យកើតឡើងព្រោះការទៅកាន់ទីព្រាត់ប្រាសដ៏ឆ្ងាយ គ្មានពេលត្រឡប់វិញដើម្បីប្រយោជន៍ដល់យញ្ញរបស់ព្រះបិតា" ។*

*គ្រានោះ ព្រះមាតារបស់ចន្ទកុមារខ្សឹកខ្សួលថា ៖*

"ហន្ទ ច បទុមបត្តានំ មោឡឹ ពន្ធស្សុ គោតមិបុត្ត
ចម្បកទលមិស្សាយោ ឯសា តេ ចោរាណិកា បកតិ ។
ហន្ទ ច វិលេបនំ តេ បច្ចិមកំ ចន្ទនំ វិលិម្បស្សុ
យេហិ ច សុវិលិត្តោ សោភសិ រាជបរិសាយំ ។
ហន្ទ ច មុទុកានិ វត្ថានិ បច្ចិមកំ កាសិកំ និវាសេហិ
យេហិ ច សុនិវត្ថោ សោភសិ រាជបរិសាយំ ។
មុត្តាមណិកនកវិភូសិតានិ គណ្ហស្សុ ហត្ថាភរណានិ
យេហិ ច ហត្ថាភរណេហិ សោភសិ រាជបរិសាយំ" ។

*"ម្នាលគោតមិបុត្រ ណ្ហើយចុះ បាឯងចូរបួងមោលី[៤០] ដោយស្លឹកឈូក ចូរប្រដាប់ផ្កាកម្រង ដែលលាយដោយត្របកផ្កាចម្ប៉ា នេះជាទម្លាប់របស់បា ។ ហ៎ បាឯងធ្លាប់លាបស្រឡាបដោយខ្លឹមចន្ទន៍ទាំងឡាយណា រមែងល្អរុងរឿងក្នុងរាជបរិស័ទ នេះជាគ្រឿងលាបរបស់បា ចូរបាលាបវាចុងក្រោយចុះ ។ ហ៎ បាឯងធ្លាប់ស្លៀកដណ្ដប់សំពត់ទាំងឡាយដែលមានសាច់ទន់ ៗ ល្អរុងរឿងក្នុងរាជបរិស័ទ នេះជាសំពត់មានសាច់ទន់ ចូរបាស្លៀកសំពត់ដែលកើតក្នុងដែនកាសីនេះ លើកចុងក្រោយចុះ ។ បាឯងធ្លាប់ល្អរុងរឿងដោយ*

៤០ (ន.) (បា.),(សំ.) (*មោលិ; មៅលិ*) *ជុក, កំប៉ោយ; ផ្នួងសក់ : កាត់មោលី ។ ខ្មែរហៅកំពូលស្រួចដែលធ្វើបរស្មីក្តួចមូលលើព្រះសិរស័ព្រះពុទ្ធរូបថា មោលី ដែរ : ព្រះមោលី; សាងព្រះពុទ្ធរូបប្រាក់មោលីមាស ។*

*ហត្ថាភរណៈ[៤១]ណាក្នុងរាជបរិស័ទ ចូរបាពាក់នូវហត្ថាភរណៈដែលវិចិត្រហើយដោយកែវមុក្តា កែវមណី និងមាសនេះចុះ” ។*

## ចន្ទាទេវីអង្វរព្រះបាទឯករាជ

*អគ្គមហេសីព្រះនាមចន្ទាទេវី បានក្រាបចុះក្បែរព្រះបាទរបស់ព្រះបាទឯករាជ ហើយខ្សឹកខ្សួលថា ៖*

“ន ហិ នូនាយំ រដ្ឋបាលោ   ភូមិបតិ ជនបទស្ស ទាយាទោ
លោកិស្សរោ មហន្តោ   បុត្តេ ស្នេហំ ជនយតិ” ។

*“ព្រះបាទឯករាជនេះ ជាអ្នករក្សាដែន ជាម្ចាស់ផែនដី ជាអ្នកទទួលមត៌ករបស់អ្នកជនបទ ជាឥស្សរៈលើលោក ទ្រង់ជាធំ តែមិនបានញ៉ាំងសេចក្តីស្នេហា ឲ្យកើតមានក្នុងព្រះរាជបុត្រដោយពិតសោះ” ។*

*ឮដូច្នោះ ព្រះបាទឯករាជត្រាស់ថា ៖*

“មយ្ហម្បិ បិយា បុត្តា   អត្តា ច បិយោ តុម្ហេ ច ភរិយាយោ
សគ្គញ្ច បត្ថយានោ   តេនាហំ ឃាតយិស្សាមិ” ។

---

*[៤១] ហត្ថាភរណៈ ឬ ហត្ថាលង្ការ (បា. < ហត្ថ “ដៃ” + អាភរណ ឬ អលង្ការ “គ្រឿងប្រដាប់”) គ្រឿងប្រដាប់សម្រាប់ពាក់តែងដៃ (មានចិញ្ចៀនជាដើម) ។ល។*

"បុត្រទាំងឡាយ ជាទីស្រឡាញ់របស់យើង ម៉្យាងទៀត នាងក្តី មហេសីទាំងឡាយឯទៀតក្តី ក៏សុទ្ធតែជាទីស្រឡាញ់របស់យើង ដែរ ប៉ុន្តែយើងចង់បានឋានសួគ៌ទេតើ បានជាយើងឲ្យគេសម្លាប់ ដោយហេតុនោះ កុំព្រួយបារម្ភអ្វីឡើយ ពួកគេទាំងអស់នឹងទៅ ទេវលោកជាមួយនឹងយើងពុំខាន" ។

ចន្ទាទេវីថា ៖

"មំ បឋមំ ឃាតេហិ មា មេ ហទយំ ទុក្ខំ ជាលេសិ
អលង្កតោ សុន្ទរកោ បុត្តោ ទេវ តវ សុខុមាលោ ។
ហន្ទយ្យ មំ ហនស្សុ បរលោកេ ចន្ទកេន ហេស្សាមិ
បុញ្ញំ ករស្សុ វិបុលំ វិចរាម ឧភោបិ បរលោកេ" ។

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់មុនចុះ កុំឲ្យ សេចក្តីទុក្ខកម្ទេចហឫទ័យខ្ញុំម្ចាស់ឡើយ បពិត្រព្រះសម្មតិទេព បុត្ររបស់ព្រះអង្គ ជាអ្នកមានគ្រឿងអលង្ការប្រដាប់ហើយ ជា បុត្រល្អល្អះ ជាសុខុមាលជាតិ ។ បពិត្រព្រះអង្គជាម្ចាស់គេ ណ្ហើយចុះ សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់ជាស្ត្រីមាន សេចក្តីសោក ដូចគ្នានឹងចន្ទកុមារ សូមព្រះអង្គធ្វើបុណ្យឲ្យ បរិបូណ៌ចុះ យើងខ្ញុំទាំងពីរនាក់ នឹងត្រាច់ទៅក្នុងបរលោកមុន" ។

ព្រះបាទឯករាជថា ៖

"ម្នាលនាងចន្ទា មានភ្នែកវិសេសវិសាល នាងកុំព្រះកន្សែងឡើយ ជនទាំងឡាយជាបងប្អូនខាងប្ដីរបស់នាងដ៏ច្រើន ជនទាំងនោះនឹងញ៉ាំងនាងឲ្យត្រេកអរ ព្រោះគោតមិបុត្រត្រូវគេបូជាយញ្ញ" ។

កាលបើព្រះបាទឯករាជ ទ្រង់ត្រាស់យ៉ាងនេះ ព្រះនាងចន្ទាទេវី យកបាតដៃទាំងគូទះទ្រូងខ្លួនឯង ពិលាបថា ៖

"អលមេត្ថ ជីវិតេន បិស្សាមិ វិសំ មរិស្សាមិ ។
ន ហិ នូនិមស្ស រញ្ញោ មិត្តាមច្ចា ច វិជ្ជរេ សុហទា
យេ ន វទន្តិ រាជានំ 'មា ឃាតយិ ឱរសេ បុត្តេ' ។
"ន ហិ នូនិមស្ស រញ្ញោ ញាតី មិត្តា ច វិជ្ជរេ សុហទា
យេ ន វទន្តិ រាជានំ 'មា ឃាតយិ អត្រជេ បុត្តេ' ។
ឥមេ តេបិ មយ្ហំ បុត្តា គុណិនោ កាយូរធារិនោ រាជ
តេហិបិ យជស្សុ យញ្ញំ អថ មុញ្ចតុ គោតមិបុត្តេ ។
ពិលសតំ មំ កត្វាន យជស្សុ សត្តធា មហារាជ
មា ជេដ្ឋបុត្តមវធិ អទូសកំ សីហសង្កាសំ ។
ពិលសតំ មំ កត្វាន យជស្សុ សត្តធា មហារាជ
មា ជេដ្ឋបុត្តមវធិ អបេក្ខិតំ សព្ពលោកស្ស" ។

"ការរស់នៅក្នុងលោកនេះ ល្មមប៉ុណ្ណឹងហើយ អញនឹងផឹកថ្នាំពិសឲ្យស្លាប់ ព្រោះថា ជនទាំងឡាយជាញាតិមិត្រ ជាសម្លាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយហ៊ានក្រាបទូលព្រះអង្គថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រទាំងឡាយ ដែលកើតអំពីព្រះឱរសដូច្នេះឡើយ ។ ជនទាំងឡាយ ជាញាតិមិត្រ ជាសម្លាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយ ហ៊ានក្រាបទូលព្រះអង្គថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រ ដែលកើតអំពីព្រះអង្គដូច្នេះឡើយ ។ បុត្ររបស់ខ្ញុំម្ចាស់ទាំងឡាយនេះ ពាក់កម្រងផ្កាទ្រទ្រង់គ្រឿងប្រដាប់ជាវិការៈនៃមាស សូមព្រះរាជាបូជាយញ្ញដោយរាជបុត្រទាំងឡាយនេះចុះ ប៉ុន្តែសូមព្រះអង្គលែងគោតមិ-បុត្រ ។ បពិត្រមហារាជ សូមព្រះអង្គកាប់ខ្ញុំម្ចាស់ ១០០ កំណាត់ហើយ បូជាយញ្ញគ្រប់ទាំង ៧ កន្លែងចុះ សូមព្រះអង្គកុំសម្លាប់បុត្រច្បងដែលជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្តឡើយ ។ បពិត្រមហារាជ សូមព្រះអង្គចិញ្ច្រាំខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយញ្ញគ្រប់ទាំង ៧ កន្លែងចុះ សូមព្រះអង្គកុំសម្លាប់បុត្រច្បងដែលសត្វលោកទាំងអស់អាឡោះអាល័យឡើយ" ។

ព្រះបាទឯករាជត្រាស់ថា ៖

*"គ្រឿងអាភរណៈជាច្រើន មានកែវមុក្តា[៤២] កែវមណី[៤៣] កែវពៃទូរ្យ[៤៤] ដែលជាវត្ថុប្រសើរនិងមិនប្រសើរ យើងបានឲ្យហើយដល់នាង ក្នុងរឿងដែលនាងនិយាយល្អ នេះជាអំណោយចុងក្រោយ ចូរមានដល់នាងចុះ" ។*

*ព្រះនាងចន្ទាទេវីព្រដូច្នោះ ក៏បានពិលាបដោយពាក្យផ្សេង ៗ ថា ៖*

"យេសំ បុព្វេ ខន្ធេសុ  ផុល្លា មាលាគុណា វិវត្តិំសុ
តេសជ្ជបិ សុនិសិតោ នេត្តិំសោ វិវត្តិស្សតិ ខន្ធេសុ ។
យេសំ បុព្វេ ខន្ធេសុ  ចិត្តា មាលាគុណា វិវត្តិំសុ
តេសជ្ជបិ សុនិសិតោ នេត្តិំសោ វិវត្តិស្សតិ ខន្ធេសុ ។
អចិរំ វត នេត្តិំសោ  វិវត្តិស្សតិ រាជបុត្តានំ ខន្ធេសុ
អថ មម ហទយំ ន ផលតិ  តាវ ទឡ្ហពន្ធញ្ច មេ អាសិ ។
កាសិកសុចិវត្ថធរា  កុណ្ឌលិនោ អគលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសូរិយា  យញ្ញត្ថាយ ឯករាជស្ស ។

*[៤២] (ន.) (សំ.),(បា.) (មុក-ក្តា, ដើង ដ) ឈ្មោះកែវ ឬត្បូងមានតម្លៃមួយប្រភេទ; ត្បូងដែលកើតអំពីខ្យង, គជ់ខ្យង; ខ្យងដាំ : កែវមុក្តា ។*

*[៤៣] (ន.) (សំ.),(បា.) (មៈនី) (មណិ) ឈ្មោះកែវឬត្បូងវិសេសមួយប្រភេទ; ពេជ្រ, ខ្យងដាំ; ច្រើននិយាយថា កែវមណី ។*

*[៤៤] (ន.) (សំ.),(បា.) (-ទូ) (វៃទូយ៌; វេឡុរិយ) ពេជ្រភ្នែកឆ្មា : កែវពិទូរ្យ, ត្បូងពិទូរ្យ ។*

កាសិកសុចិវត្ថធរា  កុណ្ឌលិនោ អគលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា  មាតុ កត្វា ហទយសោកំ ។
កាសិកសុចិវត្ថធរា  កុណ្ឌលិនោ អគលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា  ជនស្ស កត្វា ហទយសោកំ ។
មំសរសភោជនា ន្ហាបកសុន្ហាបិតា  កុណ្ឌលិនោ
អគលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា  យញ្ញត្ថាយ ឯកករាជស្ស ។
មំសរសភោជនា ន្ហាបកសុន្ហាបិតា  កុណ្ឌលិនោ
អគលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា  មាតុ កត្វា ហទយសោកំ ។
មំសរសភោជនា ន្ហាបកសុន្ហាបិតា  កុណ្ឌលិនោ
អគលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា  ជនស្ស កត្វា ហទយសោកំ” ។

*“កាលពីដើម ព្រះរាជបុត្រទាំងឡាយ មានកម្រងផ្កាវីកសំពោង មានកម្រងផ្កាដ៏វិចិត្រ ពាក់លើ-ក ថ្ងៃនេះ ព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវដ៏មុត នឹងធ្លាក់លើ-កទៅវិញ ។ មិនយូរប៉ុន្មានទេ ដាវមុខតែនឹងធ្លាក់លើ-ក នៃរាជបុត្រទាំងឡាយពុំខានហឫទ័យរបស់ខ្ញុំម្ចាស់ មិនអាចបែកធ្លាយឯណាបាន ព្រោះចំណងយ៉ាងមាំនេះ មានដល់ខ្ញុំម្ចាស់ហើយ ។ ម្នាលចន្ទកុមារនិងសុរិយ-*

កុមារ អ្នកទាំងឡាយជាអ្នកទ្រទ្រង់សំពត់សាច់ល្អដែលផលិតក្នុង ដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹម ចន្ទន៍ ចូរបុត្រចេញទៅដើម្បីយញ្ញនៃព្រះបាទឯករាជចុះ ទុកឲ្យ ព្រះមាតានិងមហាជនសោកស្ដាយ ។ ម្នាលចន្ទកុមារនិងសុរិយ-កុមារ អ្នកទាំងឡាយ ជាអ្នកសោយភោជន ដែលលាយដោយ សាច់មានរសឆ្ងាញ់ ជាអ្នកដែលគេផ្ទូតល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ចូរបុត្រចេញទៅដើម្បី យញ្ញរបស់ព្រះបាទឯករាជចុះ ទុកឲ្យព្រះមាតានិងមហាជន សោកស្ដាយ ។

# ជំពូកទី ៣

## រាជបុរសអភិសេកចន្ទកុមារឡើងគ្រងរាជ្យ

### ចន្ទាទេវីតាំងសច្ចាធិដ្ឋាន

កាលព្រះនាងកំពុងតែខ្សឹកខ្សួលយ៉ាងនេះ ការងារទាំងពួងក្នុងរណ្ដៅយញ្ញ បានចប់សព្វគ្រប់ ។ រាជបុរសទាំងឡាយ ក៏នាំរាជបុត្រទៅឲ្យអង្គុយឱន-កនៅមាត់រណ្ដៅ ។ ខណ្ឌហាលព្រាហ្មណ៍ បង្អោនថាសមាសទៅ រួចទាញព្រះខាន់ ឈរក្នុងគោលបំណងថា "អញនឹងកាត់ក្បាលចន្ទកុមារ" ។ ឃើញដូច្នោះ ព្រះនាងចន្ទាទេវីគិតថា "អញពុំមានទីពឹងដទៃទេ អញនឹងធ្វើនូវសុវត្ថិភាព[៤៥]ដល់ព្រះភស្តា[៤៦] ដោយកម្លាំងសច្ចៈរបស់ខ្លួន" រួចព្រះនាងផ្គងអញ្ជលី[៤៧] ដើរក្នុងចន្លោះបរិស័ទ បានធ្វើសច្ចកិរិយា[៤៨]ប្រកាសថា ៖

"យេន សច្ចេន ខណ្ឌហាលោ    ចាបកម្មំ ករោតិ ទុម្មេធោ

---

[៤៥] ការមានសួស្ដី, ការប្រកបដោយសេចក្ដីសុខ : បានត្រឡប់មកដល់ស្រុកវិញ ដោយសុវត្ថិភាព ។ល។

[៤៦] ស្វាមី, ប្ដី

[៤៧] (ន.) (បា.),(សំ.) (អ័ញ-ជៈ--) (បញ្ជលិ ឬប្រើជា អញ្ជលី ក៏មាន; អញ្ជលិ) ក្រពុំម្រាមដៃ (ទាំង ១០), ការផ្គុំម្រាមដៃទាំង ១០ គោរព : ប្រណម្យអញ្ជលី, លើកកំបង់អញ្ជលីប្រណម្យ (ពាក្យកាព្យប្រើក្លាយកាត់ខ្លីត្រឹមតែ ជុលី ក៏មាន : ប្រណម្យជុលី ដាក់លើសិរសី...។

[៤៨] ការធ្វើសច្ចៈ, ការប្រកាសពាក្យសច្ចៈ ។

ឯតេន សច្ចវជ្ជេន សមង្គិនី សាមិកេន ហោមិ ។
យេ ឥធត្ថិ អមនុស្សា យានិ ច យក្ខភូតភព្យានិ
ករោន្តុ មេ វេយ្យាវដិកំ សមង្គិនី សាមិកេន ហោមិ ។
យា ទេវតា ឥធាគតា យានិ ច យក្ខភូតភព្យានិ
សរណេសិនឹ អនាថំ តាយថ មំ យាចាមហំ បតិ មាហំ
អជេយ្យំ"។

*"ខណ្ឌហាលព្រាហ្មណ៍ជាមនុស្សយល់ខុស ធ្វើបាបកម្ម ដោយពាក្យសច្ចៈណា ខ្ញុំម្ចាស់ព្រមព្រៀងនឹងព្រះភស្តា តាមពាក្យសច្ចៈនុ៎ះ ។ ពួកអមនុស្ស[៤៩] ពួកទេវតា ពួកសត្វកើតហើយ និងសត្វដែលត្រូវកើត មានក្នុងទីនេះ ចូរធ្វើសេចក្តីខ្វល់ខ្វាយដល់ខ្ញុំ ខ្ញុំសូមព្រមព្រៀងនឹងព្រះភស្តា ។ ពួកទេវតា ពួកសត្វកើតហើយ និងសត្វដែលត្រូវកើតទាំងអស់ ដែលមកក្នុងទីនេះ សូមអ្នកទាំងឡាយរក្សាខ្ញុំ ដែលជាមនុស្សអនាថា[៥០] ស្វែងរកទីពឹង ខ្ញុំសូមអង្វរ*

[៤៩] (ន.) (បា.),(សំ.) (អៈមៈនុស) (អមនុឞ្យ) *សត្វអទិស្សមានកាយមិនមែនមនុស្ស គឺទេវតា, ភូត, បិសាច, ខ្មោច, យក្ស, អសុរកាយ,... (ច្រើនសំដៅភូត, បិសាច, ខ្មោច, អសុរកាយ) : ពួកអមនុស្ស; ព្រៃមានអមនុស្សកាន់កាប់ ។ អមនុស្ស ! ខ្មោច ! (ព. ស្ន. ឬ ព. ម.)។*

[៥០] (គុ.) (បា.) (អៈន៉ា--) (< *អនាថ, បុំ. --ថោ, ឥត្ថី. --ថា ឬ បុំ. ឥត្ថី. ពហុ. --ថា) ដូចគ្នានឹង អនាថ (ម. ព. នេះ) : បុរសអនាថោ, ស្ត្រីអនាថា; បុរសស្ត្រីអនាថា, ពួកជនអនាថា ។*

ព្រះភស្តា ដែលពួកបច្ចាមិត្ត[៥១]ផ្ចាញ់មិនបាន ចំពោះលោកទាំងឡាយ" ។

## សក្កទេវរាជសម្លុតស្តេចឲ្យដោះលែងសព្វសត្វ

គ្រានោះ សក្កទេវរាជ[៥២] ឮសំឡេងខ្សឹកខ្សួលរបស់ព្រះនាង ទ្រង់ក៏ជ្រាបស្ថានការណ៍[៥៣]នោះ ទ្រង់បានចាប់ដំបងដែកដ៏ភ្លឺប្រាលរន្ទាល ហោះធ្យានទៅគ្រវីបំភ័យព្រះរាជា សម្លុតឲ្យទ្រង់ដោះលែងសព្វសត្វទាំងអស់ដោយត្រាស់ដូច្នេះថា ៖

---

[៥១] (ន.) (បា.),(សំ.) (ប៉ុច-ចាមិត ឬ ប្រ័ត-ត្យា មិត) (បច្ចាមិត; ប្រត្យមិត្រ ឬ ប្រត្យានិត្រ) អមិត្ត, សត្រូវ : បច្ចាមិត្តតូចតាច អាចនឹងបង្កឲ្យកើតជាទោសសត្រូវធំបាន, ដូចជាបូសទ្រនិចតូចមួយ ឬដូចជារលកកែវតូចមួយ អាចនឹងក្លាយទៅជាជំងឺធ្ងន់បានដូច្នោះដែរ ។

[៥២] ព្រះឥន្ទ្រាធិរាជ ជាព្រះនាមទេវរាជជាអធិបតីនៃពួកទេវតាក្នុងឋានត្រៃត្រិង្សសួគ៌ ទាំងជាអ្នកមានអំណាចត្រួតត្រាលើពួកទេវតានៅឋានចាតុម្មហារាជិកសួគ៌ផង, ជាទេវរាជស័ក្តិសិទ្ធិវិសេសមួយអង្គ ក្នុងពួកទេវតាជាទីគោរពរបស់ពួកព្រាហ្មណិក, ទាំងពួកពុទ្ធសាសនិក ក៏តែងតែគោរពចំពោះទៅរកទេវរាជអង្គនេះ តាមកាលដ៏គួរម្តងៗដែរ ។

[៥៣] ស្ថានភាព; ទីតាំងនៅពិតប្រាកដ; អាកប្បកិរិយា, ហេតុភេទ, ដំណើរទំនង, បែបបទ, ដើងការ, ដំណើរការណ៍ដែលប្រព្រឹត្តទៅ; ជំហរ : ស្ថានការណ៍របស់ស្រុកទេស, ចាំស្តាប់មើលស្ថានការណ៍ សកលលោក ។

"ពុជ្ឈស្សុ ខោ រាជកាលិ　　មា តាហំ មត្តកំ និតាឡេសិំ
មា ជេដ្ឋបុត្តមវធិ　　អទូសកំ សីហសង្កាសំ ។
កោ តេ ទិដ្ឋោ រាជកាលិ　　បុត្តភរិយាយោ ហញ្ញមានាយោ
សេដ្ឋិ ច គហបតយោ　　អទូសកា សគ្គកាមា ហិ ។

*"នៃស្ដេចកាឡកណ្ណី[៥៤] ព្រះអង្គចូរដឹងចុះ កុំឲ្យខ្ញុំសំពងក្បាលព្រះអង្គឡើយ ព្រះអង្គកុំសម្លាប់បុត្រច្បង ជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ដ ។ នៃស្ដេចកាឡកណ្ណី ព្រះអង្គធ្លាប់ឃើញអ្នកណាដែលសម្លាប់បុត្រ មហេសី និងសេដ្ឋី គហបតី ជាអ្នកមិនប្រទូស្ដ ព្រោះប្រាថ្នាឋានសួគ៌ដែរឬទេ ?"*

## មហាជនគប់សម្លាប់ខណ្ឌហាលព្រាហ្មណ៍

*ខណ្ឌហាលព្រាហ្មណ៍ បានឮពាក្យនោះ ទាំងព្រះរាជាក៏ឃើញសក្កទេវរាជ ដែលព្រះអង្គមិនធ្លាប់ឃើញសោះ ទើបឲ្យគេស្រាយចំណងពីជនទាំងពួង ដូចជាមិនមានសេចក្ដីបៀតបៀនកើតឡើងអ៊ីចឹង ។ កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួកជនដែលមកប្រជុំក្នុងកន្លែងនោះ ក៏នាំគ្នាកាន់ដីមួយដុំ ម្នាក់ ៗ គប់សំដៅ*

---

[៥៤] (ន.) (បា.),(សំ.) (*កាលកណ្ណី*) *មនុស្សឥតបុណ្យ, មនុស្សចង្រៃ ។ មានប្រើក្លាយទៅជា កាឡកិណី មនុស្សធ្វើនូវនិស្ស័យនៃខ្លួនឲ្យប្រាកដស្មើដោយវត្ថុពណ៌ខ្មៅ : មនុស្សកាឡកិណី គឺមនុស្សចិត្តខ្មៅ. មនុស្សចង្រៃ : ស្រីកាឡកិណី គឺស្រីចិត្តខ្មៅ, ស្រីចង្រៃ : មេស្រីកាឡកិណី, មនុស្សកាឡកិណី ។*

ទៅខណ្ឌហាលព្រាហ្មណ៍ បណ្តាលឲ្យគាត់ស្លាប់ក្នុងទីនោះឯង ។

## មហាជនដកសិទ្ធិអំណាចព្រះបាទឯករាជទៅជាជនចណ្ឌាល

លុះសម្លាប់ខណ្ឌហាលព្រាហ្មណ៍នោះហើយ មហាជនប្រារព្ធរកសម្លាប់ព្រះរាជាថែមទៀត ។ ចន្ទកុមារពោធិសត្វ ក៏ស្ទុះទៅឱបព្រះបិតាជាប់មិនឲ្យមហាជនសម្លាប់បាន ។

មហាជននិយាយថា ៖

"យើងឲ្យជីវិតដល់ស្តេចលាមក[៥៥]នុ៎ះបាន ប៉ុន្តែយើងមិនឲ្យស្វេតច្ឆត្រ[៥៦]និងការរស់នៅក្នុងនគរ ដល់ស្តេចលាមកនោះទេ យើងនឹងចាត់ស្តេចលាមកនោះជាចណ្ឌាល[៥៧] ហើយឲ្យទៅ

---

[៥៥] (គុ.) (បា.) (--មក់) អាក្រក់, ពុំប្រសើរ, ថោកទាប, ថយថោក : អំពើលាមក, មនុស្សលាមក ។ ខ្មែរប្រើជា ន. សំដៅសេចក្តីថា "ឧច្ចារៈ" ក៏បាន : បន្ទោលាមក, ស្អុយដូចលាមក ។ ប្រើជាបទសមាស (អ. ថ. លាមៈកៈ) : លាមកកម្ម អំពើអាក្រក់ ។

[៥៦] ឆត្រស គឺជាឆត្រសម្រាប់អភិសេកឲ្យជាព្រះមហាក្សត្រិយ៍គ្រប់គ្រងនគរ ។

[៥៧] (ន.) (សំ.),(បា.) (ច័ន-ឌាល) មនុស្សពូជសូទ្រៈ ពួកមួយ គឺពួកមនុស្សត្រកូលទាបដែលមានពូជដើម កើតអំពីបិតាពូជសូទ្រៈ មាតាពូជព្រាហ្មណ៍ (ក្នុងសម័យបុរាណពីព្រេងនាយ) ។ ក្នុងសម័យសព្វថ្ងៃនេះ សំដៅចំពោះមនុស្សដែលដុនដាបថោកទាប ហើយកាចព្រហើនមិនក្រែងច្បាប់ ជាមនុស្សឥតអៀនខ្មាស ដើរសាត់អណ្តែតទៅជ្រកអាស្រ័យនៅដោយសារអ្នកដទៃ ចេញពីផ្ទះនេះទៅនៅផ្ទះនោះ ចេញពីផ្ទះនោះ

នៅខាងក្រៅនគរ ។

ថាដូច្នេះហើយ មហាជនបានដោះនូវគ្រឿងសម្គាល់ជាស្ដេចចេញ ឲ្យស្លៀកសំពត់កាសាវៈ រុំឈ្នួតក្បាលដោយក្រណាត់កញ្ចាស់ ប្រកាសទម្លាក់ទៅជាជនចណ្ឌាល ហើយបញ្ជូនទ្រង់ឲ្យទៅកាន់លំនៅរបស់ពួកចណ្ឌាល ។ ជនទាំងឡាយណា ដែលបូជាយញ្ញបសុឃាត[៩៨]នោះផង ឲ្យគេបូជាផង អនុមោទនាផង ជនទាំងអស់នោះ ឈ្មោះថាធ្វើបាបកម្ម មាននរកនៅរង់ចាំខាងមុខ ស្លាប់ហើយទៅកាន់នរក ចំណែកពួកជន មិនធ្វើបាបកម្ម ស្លាប់អំពីលោកនេះទៅ បាននូវសុគតិយ៉ាងត្រចះត្រចង់ ។

## ពិធីរាជាភិសេកចន្ទកុមារ

កាលមហាជននោះ រួចអំពីចំណាង និងបានកម្ចាត់មនុស្សកាឡកណ្ណីពីរនាក់ចេញរួចហើយ ពួករាជបុរស រាជកញ្ញា ទេវបុរស ទេវកញ្ញា បាននាំមកនូវសម្ភារៈអភិសេក[៩៩] ទុកក្នុងទីនោះ ហើយក៏ប្រជុំគ្នា

---

ទៅនៅផ្ទះឯណោះ ជាអ្នកអែបអបគ្រាន់តែចិញ្ចឹមជីវិត ប្រព្រឹត្តអំពើកាចប្រឡេងខាមជានិច្ច ប៉ុន្តែមិនប្រព្រឹត្តធ្វើចោរកម្មទេ ។

[៩៨] ការសម្លាប់សត្វចិញ្ចឹម គឺសត្វដែលគេចិញ្ចឹម ដូចយ៉ាងគោ, ក្របី, សេះ, ជ្រូក, មាន់, ទា ជាដើម ដើម្បីបូជាយញ្ញ ។

[៩៩] (ន.) (បា.),(សំ.) (អៈភិសែក) (អភិសេក) ការស្រោចទឹកក្ដស់ទឹកស័ង្ខ (លើព្រះសិរ្សលោកអ្នកមានបុញ្ញាភិនីហារ) សន្មតឲ្យឡើងពេញទីជាក្សត្រិយ៍ទ្រង់រាជ្យ (ម. ព.

អភិសេកចន្ទកុមារឲ្យជាស្ដេចឡើងគ្រងរាជ្យ[៦០] ។ កាលបើពួកជនទាំងអស់ បានរួចពីចំណង ក្នុងកាលនោះ ពួករាជបរិស័ទ ពួករាជកញ្ញា ពួកទេវបុរស ពួកទេវកញ្ញាដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។ ពួកជនជាច្រើន ត្រេកអររីករាយ ប៉ាវគងទូងអានន្ទភេរី[៦១] ក្នុងកាលដែលចន្ទកុមារចូលទៅក្នុងនគរ ពួកជនបានប្រកាសការរួចចាកចំណងរបស់ពួកសត្វ ។

## ស្ដេចចន្ទកុមារជូនស្បៀងដល់ឪពុក

ស្ដេចចន្ទកុមារ បានឲ្យគេចាត់ចែងការទំនុកបម្រុងដល់ឪពុក ប៉ុន្តែ ឪពុករបស់ព្រះអង្គ មិនត្រូវបានទទួលការអនុញ្ញាតឲ្យចូលទៅខាងក្នុងនគរបានទេ ។ ក្នុងកាលស្បៀងគាត់អស់ ស្ដេចចន្ទកុមារតែង

---

មុទ្ធាភិសេក ផង) ។ ការប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរថ្វាយពរថ្វាយជ័យចំពោះព្រះពុទ្ធរូបដែលកសាងថ្មី ក៏ហៅ អភិសេក ដែរ : អភិសេកព្រះ (ធ្វើតាមដំណើររឿងកាលដែលព្រះសក្យមុនីគោតម ទ្រង់បានត្រាស់ជាព្រះពុទ្ធរួចស្រេចហើយ, ក្នុងវេលាភ្លាមៗនោះ, ពួកទេវតានាំគ្នាមកប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរទិព្វថ្វាយពរសព្ទសាធុការថា "ព្រះពុទ្ធឈ្នះមារហើយ ! មារមានចិត្តបាបចាញ់ព្រះអង្គហើយ !" ។ ពាក្យ អភិសេក នេះខ្មែរប្រើជា កិ. ក៏មាន ។

[៦០] (កិ.) (គ្រង រាជ) បានឡើងជាក្សត្រិយ៍ជំនួសអង្គក្សត្រមុន ។

[៦១] (កិ.) អំពាវនាវប្រាប់ឲ្យដឹងរាល់គ្នា ដោយដើរវាយគងឲ្យលាន់ឮ; បើមានវាយស្គរផង ហៅថា ប៉ាវគងទូងភេរី (មានប្រើតែក្នុងសម័យបុរាណយូរអង្វែងហើយ) ។

យាងទៅប្រពាតឧទ្យាន ទ្រង់ឆៀងចូលទៅសាកសួរសុខទុក្ខឪពុក ហេតុតែទ្រង់គិតថា ទ្រង់ជាធំ ជាស្ដេច ដូច្នេះ ទ្រង់មិនថ្វាយបង្គំគាត់ទេ ប៉ុន្តែទ្រង់លើកដៃជម្រាបសួរ ញញឹមរួសរាយដាក់ មានព្រះរាជឱង្ការថា "សូមលោកឪពុក មានអាយុយឺនយូរ" រួចទ្រង់សួរអំពីសេចក្ដីត្រូវការ ។ កាលឪពុករបស់ព្រះអង្គ ប្រាប់អំពីសេចក្ដីខ្វះខាតអ្វីណា ស្ដេចចន្ទកុមារក៏ប្រើឲ្យរាជបុរសប្រទាននូវស្បៀងនោះដល់ឪពុក តាមសេចក្ដីត្រូវការ ។ ស្ដេចចន្ទកុមារ ទ្រង់សោយរាជ្យ[៦២]ដោយធម៌ លុះដល់ទីបំផុតនៃព្រះជន្ម ទ្រង់បានទៅកើតនៅទេវលោក ។

## ព្រះសាស្ដាប្រជុំជាតក

លុះនាំធម្មទេសនានេះមកបរិយាយហើយ ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះទេ សូម្បីពីអតីតជាតិ ក៏ទេវទត្ត បានព្យាយាមដើម្បីសម្លាប់មនុស្សជាច្រើននាក់ ដោយអាស្រ័យតថាគតតែម្នាក់អ៊ីចឹងដែរ" ហើយទ្រង់ប្រជុំជាតកដូច្នេះថា ៖

តទា ខណ្ឌហាលោ ទេវទត្តោ អហោសិ,
គោតមីទេវី មហាមាយា,
ចន្ទាទេវី រាហុលមាតា,

[៦២] គ្រងរាជ្យក្នុងឋានៈជាស្ដេចផែនដី, គ្រប់គ្រងប្រទេសនិងប្រជារាស្ត្រ ។

វសុលោ រាហុលោ,
សេលា ឧប្បលវណ្ណា,
សូរោ វាមគោត្តោ កស្សបោ,
ភទ្ទសេនោ មោគ្គល្លានោ,
សូរិយកុមារោ សារិបុត្តោ,
ចន្ទរាជា បន អហមេវ សម្មាសម្ពុទ្ធោ អហោសិំ ។

*-ខណ្ឌហាលព្រាហ្មណ៍ គ្រានោះ បានមកជាទេវទត្ត*
*-គោតមិទេវី បានមកជា មហាមាយា ។*
*-ចន្ទាទេវី បានមកជា រាហុលមាតា ។*
*-វសុលៈ បានមកជា រាហុល ។*
*-សេលា បានមកជា ឧប្បលវណ្ណា ។*
*-សូរៈ បានមកជា វាមគោត្តកស្សបៈ ។*
*-ភទ្ទសេន បានមកជា មោគ្គល្លាន ។*
*-សូរិយកុមារ បានមកជា សារីបុត្រ ។*
*-ចំណែកចន្ទរាជា បានមកជាអញតថាគតសម្មាសម្ពុទ្ធហ្នឹងឯង ។*
*ចន្ទកុមារជាតកពិស្តារទី ៧ ចប់ដោយបរិបូណ៌ ។*



ISBN 9789996341021

PUC Press